# រឿងកុំណាង

INSTITUT BOUDDHIQUE

ព.ស. ២៥២៤

www.elibraryofcambodia.org

HISTOIRE DE

# TUM TEAO

PAR

PREAH PADUMATTHER SOM

5.000 Exemplaires

Editions de l'Institut Bouddhique

1981

www.elibraryofcambodia.org

## អារម្ភកថា

## របស់ពុទ្ធសាសនបណ្ឌិត្យ

រឿងទុំទាវនេះ មិនមែនជារឿងព្រេង និងមិនមែនជារឿងជាតកទេ គឺជារឿងមួយកើតឡើងពីការដកស្រង់នៃបញ្ហាជីវិតខ្មែរយើង ដែលធ្លាប់មានពិតប្រាកដ ក្នុងសម័យចំរុងលង្វែក ដូចមានសេចក្ដីពិស្ដារក្នុងផ្ទៃរឿងនេះជាភ័ស្តុតាងស្រាប់ ។

វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ បានស្រាវជ្រាវរកឃើញនូវ រឿងទុំ-ទាវនេះ មានពីរបែប គឺ :

១– ច្បាប់របស់លោកគ្រូព្រះបទុមត្ថេរព្រះនាម សោម ចៅអធិការវត្តកំព្រៅ ឃុំកំព្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង តែងក្នុង ព.ស. ២៤៥៨ គ.ស. ១៩១៥ រជ្ជកាលព្រះបាទស៊ីសុវត្ថិ រៀបរៀងជាកាព្យពាក្យ ៧ ពីដើមដល់ចប់ ។

២– ច្បាប់របស់លោកឧកញ៉ាវិបុលរាជសេនា នូ-កន តែងជាកាព្យពាក្យ ៨ ក្នុង ព.ស. ២៤៨៥ គ.ស. ១៩៤២ រជ្ជកាលព្រះបាទ នរោត្តមសីហនុ តែច្បាប់របស់លោក នូ-កន ប្រែឈ្មោះថា "រឿងទាវឯក" ទៅវិញ ព្រមទាំងបញ្ចូលគំនិតផ្ទាល់ខ្លួនជាច្រើនផង ។

www.elibraryofcambodia.org

វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ បានចាត់ការចម្លងយករឿងទុំទាវ ចេញពីក្បួនសាស្ត្រាស្លឹករឹត របស់លោកគ្រូព្រះបទុមត្ថេរព្រះនាម សោម ដែលមាននៅក្នុងបណ្ណាល័យ របស់វិជ្ជាឋាននេះ មកពិនិត្យផ្ទៀងផ្ទាត់ ហើយចាត់ការបោះពុម្ពឡើង ដើម្បីរក្សាស្នាដៃកវីនិពន្ធខ្មែរសម័យបុរាណ ទុកជាកេរ្តិ៍តទៅ កុំឲ្យបាត់បង់ និងដើម្បីឲ្យអ្នកអាន :

ក) បានស្គាល់ច្បាស់ថា ជាតិខ្មែរយើង មានកេរ្តិ៍មត៌កអក្សរសាស្ត្រច្រើនបែប ពិសេសជាបែបប្រលោមលោក ប៉ុន្តែសរសេរជាពាក្យកាព្យ;

ខ) បានស្គាល់ព្រឹត្តិការណ៍អក្សរសាស្ត្រខ្មែរសម័យបុរាណ;

គ) បានបេះចាំរឿងនិទាន និងពាក្យខ្មែរបុរាណច្រើន បែកប្រាជ្ញា អាចធ្វើការចរចា និងការនិពន្ធរបស់ខ្លួន ឲ្យមានសម្រស់;

ឃ) បានប្រៀបធៀបវោហារពាក្យពេចន៍សម័យចាស់ និងសម័យថ្មី ហើយធ្វើសេចក្តីនិពន្ធន៍របស់ខ្លួនឲ្យមានលម្អ ឲ្យត្រូវគ្រប់សម័យ ។

ការចម្លង និងការពិនិត្យផ្ទៀងផ្ទាត់នេះ បានទុករឿងនិងពាក្យកាព្យក្នុងផ្ទៃរឿងឲ្យនៅតាមច្បាប់ដើម ឥតកែប្រែ, គ្រាន់តែសម្រួលពាក្យខ្លះដែលយល់ច្បាស់ថា តក់ដោយការចម្លងតៗគ្នាជាច្រើនតំណមកហើយ ឲ្យត្រឹមត្រូវតាមច្បាប់ដើមវិញ និងគ្រាន់តែប្រើអក្សរតាមវចនានុក្រមខ្មែរ

www.elibraryofcambodia.org

សម័យបច្ចុប្បន្នប៉ុណ្ណោះ ។

វិជ្ជាបានពុទ្ធសាសនបណ្ឌិត្យ សង្ឃឹមថា សៀវភៅរឿងទុំទាវនេះ នឹងបានជាកម្លាំងមួយ អាចជួយពង្រីកអក្សរសាស្ត្រជាតិ ឲ្យមានវឌ្ឍនាការជាតិយោភាពតទៅ ។

ពុទ្ធសាសនបណ្ឌិត្យ

www.elibraryofcambodia.org

អារម្ភបទ

របស់រឿងទុំទាវ

## បទពាក្យ ៧

១— នេះនឹងថាថ្លែងតែងបរបា ល្បើកល្បងល្បែងល្បាយកាយកាព្យ
តាំងតែដំណាលកាលមុនថា និទានយូរយារឃ្លាឃ្លាតឆ្ងាយ ។
មិនទៀងល្អៀងល្អកតក់ឃ្លាឃ្លាត សង្ខាតផ្ទៀងផ្ទាត់បទបរិយាយ
យើងកែជាថ្មីផែនដីកាយ ស្រង់ស្រាយតទុកទៅមុខទៀត ។
ទិតចំសទ្យកែគិតហួស ក្រែងហួសការៈស្ន័ត្រប្រឹងធ្វៀត
កុំមានពេហារថាពោលមេត្រៀត បែរបៀតត្រូវកាលដំណាលក្តី ។
នាមានាមតាំងជាថ្មី ក្នុងផែនលោកិយគន់គិតគ្នេរ
គិតគ្នាន់ក្នុងអង្គផ្គង់កាយេ គិតយកមកផ្គរផ្ទៀងទៀងទុក ។

៤— ឲ្យអស់មហាជនជាតិប្រុសស្រី ក្នុងផែនលោកិយដឹងទៅមុខ
គ្រាន់ជាលំហែកែអផ្សុក វិតក្កកាលណាក្លារីកកយ ។
យើងទឹងថ្លែងនាមតាមបញ្ហា ថើមថាតាមឈ្មោះចំពោះឆាយ
ត្ល ស ពប់រៀបធៀបនិយាយ ទើបតាយប្រកបពប់រឿងទៅ ។

www.elibraryofcambodia.org

ទាញយារ សរ់ សត្វប្រកប ម ចាំងឈើលើ ស ទើបបានត្រូវ
ឈ្មោះដើមដូចទីងពីមើន ឥឡូវនាមបែកបែកដោយគុណ ។
ចូលមកសំណាក់សំណាងមាន ព្រះគុណឲ្យទានទុកជាទុន
ជាទីគ្រាន់បានប្រាណរស់ជន្ម ដោយបុណ្យរតនត្រៃសព្វថ្ងៃពឹង ។
ចូលមកសំណាក់បួសគង់នៅ ទីវត្តកំព្រៅស្មោះសរក្ដឹង
កាត់សង្ខារវដ្តរសរាងទឹង នឿយព្រួយព្រោះប្រឹងប្រាថ្នាផល ។
១០– នាមនោះចំពោះឧបជ្ឈាយ៍ចារ្យ ដូចផ្កាក្រអូបគុំប្រាសខ្យល់
ព្រះបទុមត្ថេរបែរបានផល កំណាត់កុសលសាងសីលទាន ។
ស្ដេចសង្ឃមេត្តាត្រាប្រណី សម្រេចលើដីពេកកិយគ្មាន
នាយកខាងសង្ឃក្នុងក្រុងមាន សង្ឃផងស្រុកឃ្លានមានបញ្ញា ។
ចូលទៅដែនក្រុងផ្ទន់ស្មោះស្ម័គ្រ ប្រាថ្នាពឹងពាក់តាមប្រាថ្នា
រៀនសូត្របាលីអត្ថបញ្ហា ចិន្តាផ្គាប់ផ្គួនបុណ្យបារមី ។
ទ្រង់ប្រោសប្រទានឲ្យមានឈ្មោះ ចំពោះជាបានដូចសេចក្ដី
ប្រាថ្នាការងារប្រតិតក្ដី ប្រណីប្រោសប្រាណប្រទានមក ។
តាំងព្រះឧបជ្ឈាយ៍ងារព្រះស- ង្ឃវង្សគង់ទឹងពឹងពន្ទក

www.elibraryofcambodia.org

ពន្ទឹលោកិយនិស្ស័យជ្រក ចូលមកកាលណាពោះត្រាឲ្យ ៗ

១៩–កាន់ដើរកេស៊ុំទៅឆ្ងាយជិត មិនមានភ័យកិតទឹងចីពោយ

ប្រកាន់តែកងេរទើដើរដោយ គ្មានកាតប៉ោះឆ្ងាយឲ្យលើកជី ៗ

យើងលើកកាព្យកាលពុទ្ធសាសនា ពីរពាន់សេព្រធ្នំសិរី

ប្អូនយេហាសិបប្រាំបី ថ្ងៃចន្ទដប់ប្អូនរាប់ខួរខែ ៗ

កន្ទង់បានប្អូនជួនករុទ្ធបទ មួយកើតកំណត់សេរុត្ត

ឆ្នាំជោះសប្តស័កមិនហួរហៃ សល់តៅទៀតឯមុខមិនថ្លែង ៗ

ទុកឲ្យអ្នកក្រោយពោះលោកណា មែនមានប្រាជ្ញាចេះតុបតែង

គិតចុះសល់ទុកមិនសម្តែង ចេះអ៊ើតែងង៍ក្រែងគេថា ៗ

ចាំបែងសម្តែងរះរៀបរាប់ ទុកជាសណ្តាប់ក្នុងសាសនា

សូមលើកករផ្តិនខមស្ការ ដល់ព្រះសម្មាសម្ពុទ្ធ ៗ

២០–នូវគុណព្រះធម៌ធំទូលាយ ប្រាំបីមុនបាយប្អូនពាន់ខ្ពស់

ជ្រៅជ្រើនក្រើនត្រាច់ប្រោសប្រោះ សត្វមនុស្សជាក់ដល់ថ្នល់និព្វាន ។

នូវគុណព្រះសង្ឃអគ្គសាវ័ក លោកភ័យផ្អើលភ្ញាក់មិនស្រេកឃ្លាន (១)

បាកសង្ក្រវវឌ្ឍប្រាកដមាន ទុកដាក់ផ្ញើពានមានសង្ស- ៗ

---

១– គួរជា លោកមិនផ្អើលភ្ញាក់ភ័យស្រេកឃ្លាន ។

www.elibraryofcambodia.org

មុតិបិតជូនថៃក្នុងសាសនា ប្រៀបដូចកេគ្រារិះរៀបចំ
រកវៀនគន្ធធុរៈដាក់ឧត្តម ប្រឹងខំក្រែងខុសឆ្ពោះវិន័យ ៗ
សូមគុណព្រះឧបជ្ឈាយាចារ្យ មាតាបិតានូវព្រះតៃ-
ស្រពស្រង់រូបរស់រូបទីទៃ ឥតអ្វីប្រៀបផ្ទឹមត្រឹមស្មើបាន ៗ
នូវគុណព្រះកម្មវាចា អនុសាវនាបង្កើតប្រាណ
គុណព្រះវិន័យព្រះកម្មដ្ឋាន ដាក់ប្រាណផុតទុក្ខសុខសួគ៌ា ៗ

២៥–គុណព្រះអគ្គីវរបុត្ត ព្រះអាទិត្យធរណីព្រះចន្ទ្រា
ព្រះពាយតារាទេពទេវ ឋិតគុកគុហាសោឡសស្ថាន ៗ
ព្រះកាលព្រះយមរាជា ចតុលោបាលាឋិតសម្រាន្ត
គង់ចាតុម្មហារាជស្ថោះស្ថាន កំសាន្តគង់នៅតាវត្តិង្ស ៗ
ព្រះឥន្ទ្រាទ្រង់គង់សោយរាជ្យ រិទ្ធិអំណាចមានចេស្ដា
ទាំងសោឡសសួគ៌ទេវតា ព្រះវិស្សកម្មាប្រតិស្ឋាន ៗ
សូមសុំតេជះលោកទាំងគ្រប់ ជាម្លប់គ្រាន់ជ្រែកកោនសម្រាន្ត
សម្រេចបៀសទុក្ខសុខក្នុងប្រាណ ឲ្យបានដូចចិត្តគិតប្រាថ្នា ៗ
ទោះទាំងរោគាព្យាធិក្ដី កុំបីឲ្យមានកង្វិកាយា
សូមជ្រះស្រឡះអគ្គរូបា ភ្លឺថ្លាត្រចង់ដូចវង់ខែ ៗ

www.elibraryofcambodia.org

# រឿងទុំទាវ

## បទពាក្យ ៧

៣០– ថាថ្លែងសម្ដែងដើមឈ្មោះទុំ　　នៅខេត្តបាភ្នំដែនដីស្រែ
កើតកបទំនៀមមានឪម៉ែ　　ប៉ុន្តែហេតុម្ដេចឥតសម្ដែង ៗ
កើតឡើងលុះធំល្មមប្រមាណ　　ឆ្នាំច្រើនសោតបានម្ដាយគុបតែង
យកទៅឲ្យរៀនពោលគ្រឿងល្បែង　　ស្វះស្វែងនៅវត្តវិហារធំ ៗ
លោកគ្រូទទួលស្រួលព្រះទ័យ　　ប្រឹតប្រៀនទុំឲ្យខាងអាគម
អាចនាប់ដោយប្រាជ្ញប្រិនជ្រញ៉ំ　　ចិត្តចំចងបួសផ្នួសសាមណេរ ៗ
សំណាក់បិតចេះចំណេះលង　　មាននេនមួយអង្គគ្រាន់បើដែរ
នាមឈ្មោះនេនពេជ្រលេចក្រៃស　　នេនទាំងពីរកែតែតោគលក់ ៗ.

៣៥– ទុំមានវោហារប្រាជ្ញាផ្សេង　　មានទាំងសម្លេងរូបខ្ចិល្អ
ល្អទ្រង់អង្គកាយសាយទឹកមុខ　　រូបទុកនេនពេជ្រស្របជាប្អូន ៗ
នេនពេជ្រចេះស្រួចខាងផ្លុំប៉ី　　ឈ្មោះសាវ៉ែប្រសប់ភ្លេងមាំមួន
អ្នកនេនពីរពិតគិតគុំគួន　　បំណះគុនខ្ទួនប្រហែលគ្នា ៗ
ធ្លើតោកធ្លើទុកលក់ជាប់ខ្ទះ　　នៅផ្ទះទៀបវត្តជាម៉ង់មា
លុះដល់រដូវត្រូវរដា　　ព្រឹប្រូនអង្គាជាទុកព្រួយ ៗ

www.elibraryofcambodia.org

អកុសលដល់គ្រប់សង្កត់កាយ ជួបនេនពេជ្រកយដូចខ្ញុំមួយ
ថានេនពេជ្រអើយប្អូនគាត់ជួយ យើងលក់ពោកមួយៗយូរហើយ ។
ក៏គ្មានចំណេញជំនួញទាល់ កុំឆ្ងល់ដូចពាក្យបុណ្ណាឡើយ
ថានៅរៀងកាយជិតបង្កើយ លំហែលំហើយតែប្អូនស្រី ។
បុណ្ណាលោកថាមិនខុសសោះ ខ្ញុំនេះយើងគម្មោះកូនលោកិយ
បួសស៊ីបាយបាត្រមិនបេះត្បី នៅថ្វីពោលម្សៀតផ្សៀតដើរឆ្ងាយ ។
៤០-គិតស្រេចព្រមព្រៀងមៀងមើលគ្រប់ ទំទប់មិនឈ្នះរៀបខ្វល់ខ្វាយ
ទៀនធូបបានស្រោចប្រញាប់កាយ ឡើងដាក់អង្គថ្វាយបង្គំគាល់ ។
លោកគ្រូពុំយូរមានពុទ្ធដីកា ថានេះទៅណាដូចពីកាល់
នេនទូលពុទ្ធដីកាថាទាំងទាល់ ក្រាបទូលកុំឆ្ងល់សូមមេត្តា ។
ព្រោះយើងទាំងសងប៉ងបង្គំ លាព្រះគុណជំទុំករុណា
ទាំងពីរនាក់ទិសបរិយាត្រា ប្រែប្រាសប្រាណមានការទៅស្រុកឆ្ងាយ។
នៅវត្តប្រាកដជាអផ្សុក ជាទុក្ខគ្មានល្ហែកងអង្គកាយ
ខ្ញុំលាណាស់ព្រះគុណមិនសប្បាយ ក្រហល់ក្រហាយខ្វល់ចង់ដើរ ។
ដោយសារត្រូវខ្យល់ដល់រដូវ លាព្រះគុណទៅក្រែងប្រសើរ
ប្រសិនដឹកគោកយកទៅផ្ញើ គ្រាន់បើនៅកាយតាយមិនដាច់

៤៩- លោកគ្រូតុំយូរមានពុទ្ធដីកា ថាអើតាមអាប្រាថ្នាគ្រាប
ថាពកអញទៅលក់ដូរស្រេច ចាំបាច់សាស័ព្ទប្រាប់អញថ្មី ៗ
ទៅចុះតាប់ខុសប្រយ័ត្នណា៎ កុំរីយអីអាឃើញរូបស្រី
បតបួបឡូកះលេងមិនគប្បី ជំទៀលអប្រិយផលមកគ្រូ ៗ
កើតខ្មាសនិន្ទានាលោកិយ ខុសពីវិន័យព្រះសព្វញ្ញ
បើទៅលក់អស់កុំនៅយូរ គិតគូរថ្ងៃថោកមកវិញឆាប់ ៗ
ខេនទាំងពីរកាយថ្វាយបង្គំ លាលោកគ្រូធំចុះប្រញាប់
ប្រញាយប្រញឹកទឹកឃើញស្រាប់ យកគោគរៀបផ្កាប់ផ្គងបម្រេង ៗ
ផ្ទុកកន្ទរមេះរេះរេកបាយ បានខ្ចប់ខ្ចល់ខ្ចាយរេកការុង
បង្ការប្រេកស្រូវក្រេងផូរផុង ត្បិតកន្ទេរដូវត្រូវក្បៀងផ្គរ ៗ
៥០- ខេនរៀបបម្រុងការុងបាយ បង្ការទៅឆ្ងាយផ្លូវត្រាច់ចរ
ប្រឹងអូសរទេះមកបញ្ឈរ ដឹកគោទឹមបរចេញទៅ ៗ
ពារពេលប្រហែលម៉ោងប្រាំបី សូរសៃងរង្សីក្រឹសឡៅ
សន្ធានទិសបូព៌ាប្រាបង្អៅ បរដល់វាលទៅក្នុងខេត្តខ័ណ្ឌ ៗ
មើលមានទឹកស៊ៅខាងផ្លូវស្រាប់ ប្រញាប់ដោះគោបង់ខេនឆាន់ ៗ
គោស៊ីស្មៅស្រេចដឹករន្ទាន់ ប្រកាន់ចូលទឹមទឹមបរទៅ ៗ

www.elibraryofcambodia.org

ដល់ស្រុកភូមិស្ថានបានលក់គោក  បាសកទិញយកខ្វះសល់នៅ
សល់ខានប៉ុន្មានលក់តាមផ្លូវ  ខំបរដល់ទៅខេត្តត្បូងឃ្មុំ ។
៥៩–ប្រទលដែនដល់ខេត្តចិន  ថ្ងៃគង់ឈប់ទីងផ្សារជនជុំ
បង់ទិញគោកនេនខ្វះគន់គុំ  សម្ដឹងនេនទុំសមរូបឆោម ។
ខ្វះជាអើម្ល៉េះប្រុសិនណា  បានអញប្រវ៉ាទុបប្រលោម
ប្រវៃឡូងតាមចិត្តគិតបង់ហោម  តៀងមើលព្រឹព្រមប្រឈមឈប់ ។
បៀតបែរស្នេហ៍ស្និទ្ធជិតអណ្ដាន  ជ្រួលប្រូងស្រើបស្រួលទំនួលម្ដប់
ឈ្មោះពោធិ៍ដើងខាលត្រកាលត្រប់  មើលសព្វស្រីប្រុសស្រុះស្រើបស្រាល ។
នេនដាក់ស្នាក់ស្និទ្ធជិតភូមិស្ថាន  ប្រមាណបាសកជួយឈើផ្កាល
លក់ដាច់ដោយយល់ឃើញត្រកាល  បណ្ដាលបណ្ដោយឲ្យយូរនៅ ។
ឈប់នៅគង់ខានបានប្រើនថ្ងៃ  គាល័យអ្នកនេនមិនឲ្យទៅ
ពាក់ទីដែនមោះព្រោះយល់ត្រូវ  រផ្លូវដល់ផែលប្រហែលជា ។
៦០–ប្រមាណដោយគិតគំនិតអ្នក  ដែលឲ្យនេនស្នាក់បង់ប្រាជ្ញា
ប្រយោជន៍ឲ្យនេនមើលសាស្ត្រា  នេនមានប្រាជ្ញាចេះលេខខាយ ។
សម្ដេងផ្លែមល្ហែមស្រួយពីរោះ  ស្ដាប់ចាំងគម្ពោះចាស់មេម៉ាយ
ក្រមុំត្បូងឃ្មុំតែប្រញាយ  ប្រញាប់បង់ស្ដាប់សព្វកាសា ។

www.elibraryofcambodia.org

កាលនោះនាងនៅជាពិលៀង   នាងទាវបានឈៀងបរយាត្រា
កាន់ក្អមបិតប្ចុមទឹកប្រាថ្នា   ចូលទៅស្តាប់ការណ៍ដឹងសេចក្តី។
ឈរទ្រឹងរង្វើខ្លួនពួនចាំស្តាប់   ពិកេះហាក់ផ្កាប់មុខដល់ដី
ស្រងាកស្រងោចស្រងល់ស្រី   នោះទឹកបេតីមិនស្តីសោះ ។
បាំទៅដល់ផ្ទះប្រាប់ទាវគ្រប់   ទាវនៅក្នុងមួប់សមស្រណោះ
នាងជាម្តាយទាវមានរបស់   កូនស្រស់រូបស្រេចផាប់ស្រីផង ។
៦៥— នោះទឹកក្នុងចិត្តគិតស្រេចស្រាប់   ដងទឹកខ្វល់ធាប់ដើរផ្សៀងផ្សង
ដល់ផ្ទះនោះឡើងទៅជាម្តង   សាសនីពយកប់ប្រាប់ទៅថា
ទាវអើយទាវស្រីសេចក្តីនេះ   លោកនេននោះបេះមើលសាស្ត្រា
សម្ងំស្រួយស្រាប់ស្តាប់គាថា   ដូចសត្វសារិកាពិសាចេក(១) ។
ទាវទៅទៅយូរគួរពិកាល់   មិនយល់គេប្រាប់ជាក់ហើយគ្រេក
គ្រន់ណោះកុំខ្វល់បានដឹងពេក   តម្រេកចង់ស្តាប់ហ៊ានប្រាប់ម្តាយ។
បេញមកក្រៅក្រោបទៀបមាតា   ទាវថាម៉ែអើយអើម៉ែអាយ
អាណិតកូនបង្ហើបកូនភ័យ   ហួសកយើងគាយឆ្ងាយវត្តបាន ។
មិនដែលស្គាល់សោះកម្ទោះលោក   មិនដឹងថាមកពីឋាន
ព្រះនោះគេថាតាគង់ប្រណា   សម្រាន្តកាយយកលក់តោកលេង។

១— បោះលើកមុនថា "សត្វសារិកាឬញ្ញាចេក" តែនេះ កែតម្រូវតាមសាស្ត្រាដើមវិញ។



www.elibraryofcambodia.org

ថាមកពីឆ្ងាយដល់ឆាយស្នាក់ ផ្ទះគេមួយជាក់ជាខេនក្មេង
ពីកោះមែនដឹងផ្សែងតាមឈ្មួង នោះជាសម្ដេចមានគ្រាន់បើ ។
៧០– នាងជាម្ដាយតាវផ្សៀងស្ដែងស្ដាប់ ឮតាវកូនប្រាប់ឆ្លើយថាអើ
លូកដៃយកស្បៃដណ្ដប់ដើរ ញាំងញុំឆ្មៀងឈ្នងទំនងតាស់ៗ
បានដល់យល់មនុស្សស្រុះជៀវនោ ម្ដាយតាវថាទមែនជាក់ច្បាស់
ទៀងទៅឃើញខេនតួបល្អណាស់ ផ្ទុំហត្ថសំពះក្រាបបង្គំ ៗ
ហើយទូលសួរថាករុណាម្ចាស់ ទិមន្ទទៅផ្ទះសត្វជាខ្ញុំ
ឆាន់ស្ងាបានម្ដងហើយយើងសុំ ទិមន្ទលោកកុំខានណាម្ចាស់ ៗ
ខេនទុំបានស្ដាប់ស័ព្ទញោមមន្ទ ក្លែកកនៃងគយគន់មើលឲ្យច្បាស់
ឆ្លើយថាបើមន្ទញោមរហ័ស ទៅផ្ទះរៀបរួបអាបក្ដីទៅ ៗ
ម្ដាយតាវវិលដល់ផ្ទះមីមា លាតលាកខ្នុលក្រាលដោយខ្នូរ
យកកែបកល់កើយខ្នើយពួបៅ សឡៅគ្រីបម៉ាក់ជាក់ដងផ្ទៃ ៗ
៧៥– ខេនតេជ្រខេនទុំដំនុំព្រម ខេនតេជ្រថាល្មមឆាន់ទៅផង
ទុំថាចុះគោនៅកន្លែស្រែ ងាបខ្សែស៊ីស្រូវត្រូវសងគេ ៗ
ខេនតេជ្រតបថាអើទៅចុះ បើខុសធានរួចខ្លួនទេ
ក្រែងរីបេទៅឆ្ពាលោកគ្រូជេរ ថាឯងវេះវើដើរបង់ស្រី ៗ

www.elibraryofcambodia.org

កាត់ដើរគ្រប់ខេត្តហេតុទាំងម៉្លេះ អាងមានតម្រិះគង់លោកិយ
ហោធាទំលើកមិនគប្បី ទំនៀមចាស់ស្ដីមិនបេះខុស ។
ថាដើរមានបួនខ្លួនជាសង្ឃ ទើបបានត្រូវគ្រង់ឥតមានមោះ
បើដើរទៅក្ដីបាសកសោះ គេរកោះថ្លោះធ្លោយឲ្យមានប្រាំ ។
នេះទៅម្នាក់ឯងក្រែងគេថា បាសកសិកាគេមកផ្ដាំ
ឲ្យមន្ដទៅលេងធានស្មាថ្មាំ មន្ដបុះធានចាំគោម្នាក់ឯង ។
៨០- ខេនទុំនឿងនឹងជ្រាំគិត ព្រួយចិត្តឡិតពេជ្រលេបសម្ដែង
យកសត្វទំនៀមមកថ្វាថ្វូង រូបទុំតុបតែងស្បង់សង្ឃាដី ។
សឹងត្រែស្សួគ្រសុទ្ធសាច់ល្អស្អាត លាំងកៃមូតមាត់ពណ៌លឿងខ្ចី
សម្បុរស្រៀបស្រស់ដុះរស្មី ខោប្ដឹក្ដីទងគតែងស ។
ស្លៀកពាក់គ្រលុំធុំរមៀត យកផ្ដិតសិកសៀតរូបឆោមល្អ
យាមឈ្នួនទំនងលើកបងក ស្រេចបរិហាកទីលីលាទៅ ។
ដល់ផ្ទះម្ដាយតាវចុះមកធាប់ ដល់ដីខ្មែរក្រោមប្រណម្យទៅ
ថាតានលោកម្ចាស់និមន្ដត្រូវ ឥឡូវឈប់រង់ស្រង់ទឹកអាង ។
ទឹកអប់គ្រឡប់ធុំគុនស សាប៊ូដួនដុសជ្រះសន្ធាង
ក្រអូបសាប៊ូក្លិនដោយយ៉ាង ដោយយល់សំណាងសាមណេរនេនៗ

www.elibraryofcambodia.org

ស្រន់ស្រេចផ្កាសស្បង់អង្រែគពាក់ ឡើងផ្ទះផល់ផាក់អន្តពន់ពេន
លើកហ្វាទបត់ថៃបកែបប្រគេន ប្រគល់លោកនេនប្រគេនស្វាៗ
ប្រាកដបេះបទយ៉ាងម្តេចខ្វះ កុំអន់អៀនខ្មាសសូមមេត្តា
និមន្តស្វ័ត្របួមើលសាស្រ្តា យើងខ្ញុំប្រាថ្នាចង់ស្តាប់មួង ៗ
ឲ្យអស់ចំណោះបេះយ៉ាងណា តាមលោកមេត្តាស្រាយចំណាង
ចំណាំម្តេចខ្វះខ្ញុំប៉ុនប៉ង សន្តានមកផង់ស្តាប់កល់គ្នា ៗ
រូបនេនស្តាប់ផាក់ក្បាក់ព្រើតប្រឹង ក្អែកគន់សម្លឹងទៅមាត់ទ្វារ
យល់តាវឈរស្លូបដើររេក ស្ទុះស្វារចូលក្នុងស្ទុះចេញក្រៅៗ
៩០– អើតអើមផកកប្រុហមាត់ ចង់ចេញប្រាកដគ្មានគេហៅ
ស្ទុតស្ទឹងម្នាក់ឯងដោយក្តៅសារ ស្ទុះចូលយកតាវពាក់ពានា ៗ
នេនយល់ដូច្នោះក្នុងពោះព្រួច កាំឧក្ខបកើតទុក្ខប៉ុកនុក
ទរូបហ្នឹងហើយតាវពុំផា មិនផាកបំពាបំពោរ ៗ
តាំងផាននមោតស្សប៉ីបទ ពិកេះប្រាកដខ្វះក្រាបនុន
ស្នូត្រក័ណ្ឌមគ្រើកាលផ្ទតគោន លំទោនលាព្រះលះបួលព្រៃ ៗ
គ្រាប់កាត់ក្នុងផងវៃនបត្តា រកបេះផលាពតាល័យ
មានរុក្ខទេវផងផទៃ បក័យស្ទុតស្ទុនក័ន្តកាំងកិត ៗ

www.elibraryofcambodia.org

ដល់ផ្លូវដាក់អង្គទ្រង់វិយោគ　　ខ្ញុំយំទទះឈ្លោកគួរអាណិត
អនាថត្រជាក់ហើយល្ហួចឥត　　លោកណាជួយគិតជីវិតខ្ញុំ ។
ប្រាសព្រះព្រោះលះមកឆ្ងាយហើយ អម្ចាស់ថ្លៃអើយម្ល៉េះក្រាលក្រំ
ព្រួយប្រឹងគិតកូនខានបង្រ្កឹម　　កូនយំទារគេយកអ្វីឲ្យ ។
៩៩–ស្រែកឃ្លានគ្មានសល់ផលផ្លែឈើ ម្ល៉េះហើយទ្រង់ដើរកើដង្ហោយ
ហៅខ្ញុំពីព្រឹកទឹកខានសោយ　　សមដោយតាមកូនសូឲ្យស្ងប់ស្ងាត់ ។
នេនស្បូត្រប្រូតកាត់កៃទំនង　　រម្ទង់យកខាងរឿងបរមត្ថ
ឈប់ផាន់ស្លាមួយរតិបក្ដាត់　　បាសកប្រតិបត្តិសត្វញាតិញោម ។
បាសកកាលនោះស្រុះស្រួលស្រេប ខ្លះស្ដាប់តាំងដាប់ទាំងផ្ទុះនោម
ពីរោះស្រណោះផ្អើលផៀវពោម　　ប្រឈមឈរឈប់មួប់មុខផ្ទះ ។
ហើយថាមេត្តាប្រាយប្រោសសត្វ　　ខ្លះខិតចូលជិតគិតបង់ឈ្នះ
លើកហត្ថទាំងសងផ្គង់សំពះ　　សូមមន្តអម្ចាស់ច្បាស់រឿងអ្វី ។
មេត្តាកុំលាក់ជាក់ជាបេះ　　ខ្ញុំមានតម្រិះត្បិតឃើញស្រី
ទារយកផាហ៊ុមព្រែកមឿ　　ផន្ទាប់ទិញថ្មីបារីស្លា ។
១០០–បត់បែរតែងស្រាប់ចាប់លើកផ្គង បិទទូលបីដងបង់ប្រាជ្ញា
ថាសូមតេជៈព្រះករុណា　　សូមជួបសម្តាចបិតានាផ្សង ។

www.elibraryofcambodia.org

សូមជួយឲ្យជួបរូបរួមកាយ   កុំឲ្យឃ្លាតឆ្ងាយជួបបំណង

ជាតិនេះជាតិណាសត្យាប័ន   បានជួបបំណងចងមេត្រី ។

ទាវរៀបផ្គងស្រេចចាប់កាន់ដើរ ដល់មកជិតសេដ្ឋីនីនោស្រី

ជាហ៎ ! នោបង្ហូរប្រណី   ប្រគេនបារីស្លា ជាហ៊ុម ។

ឲ្យខ្ញុំជាគុណជាបុណ្យខ្វះ   កុំឲ្យខ្ញុំខ្វះទ្រព្យពូលជុំ

ជាតិនេះជាតិក្រោយឲ្យមានធំ   កុំបីឲ្យខ្ញុំក្រតទៅ ។

នេនទុំទទួលគ្រឿងបរិក្ខារ   ស្រេចស្រាយយកស្លាធាន់រួចទៅ

ឈប់អង្គុយបង្គិចសែកប្រេងមៀ   រំលឹកដល់ទៅមន្ទសារិកា ។

១០៩– លិខិតជានិករវិករំលឹករក   សម្ពិលិហៅយកមណីចិន្តា

លូកយកប្រទាលឆាន់ទឹកស្លា   សូត្រសាគ្រប់សព្វចប់ជាម្ដង ។

រួចនេនទុំសូត្រស្រូតបង្ហើយ   សូត្រហើយទឹករករៀងប្អូនបង

ឃើញត្រង់ព្រាហ្មណ៍ពោរគន្ធ   នាំកុមារចងទឹងរល្ងើ ។

បណ្ដើរដើរទៅសួរគណិត   ទួញយំគន់គិតជាទុថ្ងៃ

នេះហើយព្រាហ្មណ៍ពោរបង្រៃ   រាយក្ស័យហើយណា មាតាខ្ញុំ ។

ចរចេញតាកចេរពីសាលា   អគ្គមាយប្រាជ្ញារកសន្សំ

បេះផ្លែឈើបានអគ្គបារម្ភ   ទិតទំព្រោះកូនសួនមកតាយ

www.elibraryofcambodia.org

កុមារតូច ៗ ដូចនេនទុំ　　សូត្របានផាំហ៊ុមរុំមិនស្រាយ
យកផ្កាបន្ទាល់ពារមិនស្ដាយ　　សូត្រចប់កប់កាយរួចកត្ដា ៗ
១១០-បុរាសកសំពះខ្ទះផ្លូតទុំ　　លំនៅត្បូងយំខ្ញុំរក្សា
សុំជាកូនធម៌ខ្ញុំករុណា　　មេត្តាអធ្យាស្រ័យប្រណី ៗ
នេនសូត្រសូត្រចប់ត្រឡប់សួរ　　ញោមអើយគាប់គួរត្រូវគាប់ក្ដី
លាអស់ញាតិញោមទាំងប្រុសស្រី　　ត្បិតថ្ងៃខ្ទង់ទាបរយោបយប់ (១) ៗ
ត្បិតទុកនេនពេជ្រនៅម្នាក់ឯង　　ចាំបែងចិត្តបែកបែកទាំងគ្រប់
ទាំបចិត្តគេផែរថៃមិនឈប់　　គិតសព្វគេសោតនេនដូចគ្នា ៗ
នេនទុំនាំហេតុនិយាយប្រាប់　　បុរាសកផងស្ដាប់ហើយលាគលា
ចរចុះដើរដល់នេនពេជ្រជា　　បូនអើយម្ដីមាជាដូចដើម ៗ
ចូលជិតទុំគិតនិយាយលេង　　ឲ្យពេជ្របានឈ្លើងផ្អួតទារផ្ញើម
ថានេនពេជ្របួនប្រុសថ្ងៃថ្មើម　　ទុំផ្ដើមប្ដេជាសិកាទារ ៗ
១១៨-ផាល្អណាស់ណាបួនសំឡាញ់　　ឥឡូវចង់កាញ់គិតបង់នារ
ស្ដីគេទៅសួរគួរព្រានព្រារ　　ឲ្យផឹងសុំជាវផ្ញើបញ្ចាំ ៗ
ចិត្តទារឲ្យខឹងទ្រង់ឈប់រង់　　យើងទៅហើយគង់តែផល់ឆ្នាំ
លាណោកគ្រូសឹកត្បិតយើងផ្ដាំ　　ទារទុកចំណាំខឹងរំលមក ៗ

---

១- រយោប = ទាបៈទាំ, ផិតផិល់ : រយោបយប់ = ទៀបនឹងយប់ ។

www.elibraryofcambodia.org

នេនទាំងពីរពិតគិតស្រេចហើយ    ពុំលង់យូរឡើយនេនទុំកុក
ប្រាប់ថាពេជ្រប្អូនល្មមយើងរក    ប្រមូលស្រូវយកប្រគុគារុង ៗ
លើកដាក់រទេះកុំស្ទេះឈប់    ល្មមវិលត្រឡប់ត្បិតនៅសុង
នៅសុខស្រុកអាយឆ្ងាយអន្ទង់    យើងកុំបង្អង់រង់មិនបាន ៗ
នេនទាំងពីរពិតគិតវិលវិញ    ព្រឹកព្រានចរចេញមិនមានខាន
រូបណាញាតិញោមទាំងប៉ុន្មាន    ចរព្រានដល់ដានដងមាគ៌ា ៗ
១២០-បរកាត់ត្រូវត្រង់បង្អន់ឈប់    នេនទុំជ្រួលជ្រប់ជ្រកវេទនា
ក្រៀមក្រំទទប់សញ្ជប់ជា    ទុក្ខណាស់ក្តុកក្តាករស្រោយ ៗ
បណ្ដើចរើបរុំផ្ទុំក្ទុនផ្កា    ហត្ថាទាញយកមកជិតកាយ
រូបយល់ដើមឈើផងទាំងឡាយ    កប់កាយវៀចកព្ភាប់តម្រូវ ៗ
ទះដើមទន្ទាប់ទន្ទាមក    ដើមធ្លកទុំសោកសព្វតាមផ្លូវ
ដើមថ្នាន់បានជួបដល់ឥឡូវ    ប្រាសចាវឲ្យនៅតែម្នាក់ឯង ៗ
ខ្ចិនផ្កាអ៊ីអឺដល់ម៉េះ    ក្រអូបផ្កាម្ទុះប្ដូផ្កាស្លែង
អប់នៅផាហ៊ុមទាវតុបតែង    ដាក់នៅកន្សែងចំបែងចង់ ៗ
ចាកពេលទាវស្រីសេចក្តីចាល់    មិនដែលឃើញស្គាល់ទុំជាសង្ឃ
ហ៊ានកាត់ចិត្តជ្រៀតជ្រៀតតម្រង់.    បួជាផ្ចិតផ្ចង់ឈ្ញប់ប្រាថ្នា ៗ

www.elibraryofcambodia.org

១២៩-ផ្ទាប់ក្រមួនជួនពាសពេញ ទាវតើយទុកអញម្នេញខ្មោចផ្សា
កើតទុក្ខទៀតថ្មីបារស្មា ទាវស្រីស្នេហាប្រគេនមក ។
ឥឡូវយល់សត្វប្រវាត់ទំ ឈ្មោលញីយាសយំហើយហើរគេ
បឹកបាច់ផលាប្រាថ្នាយក ដល់កូនចូលជ្រកក្នុងរូងរន្ធ ។
បញ្ចុកកូនតាប់អក័ព្វអញ ម្ល៉េះទាវគ្នាន់ក្នាញ់ជាទុក្ខធ្ងន់
ទុក្ខមិនថ្ងបស្បើយល្ហើយស្រាកស្រន់ បូជាវៃបរប៉ន់ទេវារក្ស ។
សូមសុំប្រាថ្នាជាឲ្យអញ វិលវិញត្បិតទាវនាងស្មោះស្ម័គ្រ
ឥឡូវអាចក្តីមកឈប់ស្នាក់ ធុរៈក្នុងអង្គស្រយង់យំ ។
ស្រេចហើយខេនពេជ្រគេចហៅថា ទុំកុំសោកាគិតបារម្ភ
ទុក្ខក្តីស្រីទាវនាងរៀបចំ នរណាហ៊ានបំព្រាត់ទាវទៅ ។

១៣០-រួចយកគោមកទឹមរទេះ បររេះវាងរកកាត់តម្រូវ
តម្រង់ដោយដានលំអានផ្លូវ បរត្រូវក្រង់ក្នុំជ្រៃស្រឡៅ ។
ស្រឡាំងកាំងគិតគិតទៅទៀត ចង្អៀតទុកផ្សាខ្មោចក្តៅ.
ស្រងាត់ស្រងោចស្រងូតសៅ បងមើលឃើញស្មៅស្មាច់គ្រោចគ្រស់
ទងឈើតាលគ្រង់អង្គអញបែក នាងផ្អែកអញផ្អូកក្នុងស្រណោះ
ដើមផ្តៀកអញផ្កាសប្រាសថ្ងៃកសោះ កកោះក្រគិតឥតមានស្បើយ ។

www.elibraryofcambodia.org

គគីគេគោកដួចកេគអញ　ក្តួលក្តៅពោរពេញចុកណែនហើយ
ហៅថានេនពេជ្រសំឡាញ់អើយ　ពេជ្រគ្មានធ្ងន់ធ្វើយកឡើយទប់ ៗ
ជាទុក្ខដួសទុំយំទាំងសង　ទំថាសាសន៍ទុំអើយឈប់
ចាំផល់វត្តស្ថានបានយូរយប់　យើងគិតគោរពបង្គំលា ៗ
២៣៩-ទូលលោកគ្រូយើងទំនើងថា　លាសឹកមានការព្រោះវេទនា
កុហកថាញាតិញោមមិនថា　កើតព្យាធិកេតាជាទុក្ខធ្ងន់ ៗ
អ្នកនេនទាំងពីរនិយាយគ្នា　បស្រែតម្មីមាពារពេលពន់
ទេរពាបត្រជាក់អ្នកគយគន់　មើលព្រះសូរ្យយ៉េនកំទន់ទៅ ៗ
បៀតបែរប៉ាំងបាត់សត្វបរចូល　ជិតជិះកំពូលគិរីនៅ
ទីទិសបស្ចិមបែរសំដៅ　ឈ្មោះហៅសុមេរុកជគិរី ៗ
បរបានដល់វត្តប្រាកដឈប់　ល្ងមពេលព្រលប់ចូលក្នុងទី
ឈរឈប់ដោះគោលែងទាំងពីរ　ឲ្យស៊ីស្មៅទឹកក្នុងទីស្ថាន ៗ
ហើយនេនពេជ្រទុំដំនុំនៅ　នេនផងចូលទៅទាំងប៉ុន្មាន
សន្ទនាសួរគ្នាថាសុខប្រាណ　លក់ដូរតើបានស្រូវប្តូរប្រាក់ ៗ
១៤០-ប្តីយកគាក់លុយប្រថុយថា　ប្រាប់ផងកុរុណាឲ្យគ្រន់ជាក់
គ្រូវចិត្តជឿតនេនពីរកក់ទាក់　ថាបានប្រឡាក់ប្រឡូកព្រម ៗ

ជាស្រូវជាស្រីជាល្អីប្រែង  ជាដ័រជាស្នែងជាផ្ទាំងក្អម
ជាឈ្នួតជាហ៊ឹមទឹកឃ្មុំល្មម  កន្ទ្រង់សោតព្រមតែថ្ងៃគោក ។
ហើយនេនគិតគូរពុំយូរលេង  នាំគ្នាតម្រង់ទៀងទៅគេ
ថ្វាយបង្គំគ្រូផងជាក្រោក  កើនគង់លួកយកទឹកលុបក័ក្រ ។
នេនពីក្រោមទុនលំនោនពាប  សុំគាពខ្វាបគ្រូទើបកើនក្បាក
បារម្ភក្រែងខ្វាល់លោកភ័យផាក់  ស្រេចហើយបែរក័ក្រុចតទៅសួរ ។
ពុទ្ធដីកាថានេនពេជ្រទុំទៅ  លក់ផ្ទូរដោយនៅតាមសមគួរ
បាសកងខាយភ់ភ្លើងផ្គួ  ប្តូរទិញផ្ទូរទៅកល់ខ្លួន ។
១៤៥-នេនថ្លើយសង់សបតបទូលទៅ  ក្រាបទូលបានស្រូវគ្រប់ចំនួន
បំណាញគោកស្នានជាប្អូន  សមសួនល្មមកែតែគ្រាន់ពាយ ។
នេនក្រាបទូលគ្រូគួរសព្វគ្រប់  រួចណាត្រឡប់វិលប្រញាយ
ដើរផល់គុជស្ពានសម្រាន្តកាយ  ប្រះប្រាណនៀយណាយទឹកទារទៀត ។
ថ្ងៃងថាអទ្ធិប្វាជាកម្មស៊ី  ខុកកើតជាថ្មីទ្រុងបង្អៀត
លួកយកផ្ហាហ៊ឹមដែលរុំសៀត  ទុំធ្មៀតបើបថែប្រែប្រះប្រាណ ។
ក្លិនក្អែបអែបអប់ត្រឡប់ផ្កា  ទុំយកហាតាក់កាន់បាន
យកមកទុកគ្រប់គិតស្មាន  ជាបានគ្រាន់តែល់បែបទុក្ខ ។

www.elibraryofcambodia.org

ទុំជាផ្កាបុប្ផាផង ឆរធំល្អប់ល្អងបងគ្មានសុខ
ផ្គុំផ្ការំពេងដេកមិនលក់ ពិសោរត្រេប់មុខបុកខ្ទក ៗ
១៥០-ខ្វៃរ៍ស្រមៃវិស័យទៅ ជួបពៅជួនបានក្សាន្តចិន្តា
ម៉ៃមន្តបងសូត្រមទ្រីបាពិ បួនបានបូជាផ្កាឈើផង ៗ
បូជាព្រះធម៌ធំសាយសព្វ បួនគប់ផ្កាហ៊ុមប្រគេនបង
បូជាពុំធាទាន់តាវផ្សង ឲ្យជួបគញផងបងប្រាថ្នា ៗ
ឥឡូវគាបក្តីឃ្លាតតាវហើយ តាវអើយខ្វល់ទុក្ខខាំងខ្លោចផ្សា
តាវទប់មិនឈ្នះអន្ទះសា មិនមានហើយហានិយាយស្តី ៗ
បងអ្នកប្រមាណតាវបានទោ គាត់(១)ជួយគិតគូលំហៃស្រី
រំលឹកមិនឲ្យតាវបុះជី ក្រែងខ្ញាដំរេសគ្គុំខាំ ៗ
ប្តីតាវល្អបរត់ប្រាកផមក តាមបងជ្រែលជ្រេកមិនបានផ្តាំ
គ្រាន់តែសម្គាល់បន្ទាល់ចាំ ដោយថ្នាំដោយស្លាដោយផ្កាឈើៗ
១៥៥-ដោយបានបូជាផាហ៊ុំមក ឥឡូវបងក្នុងគ្រប់អន្ទើ
លន្ទន់លន្លោចគ្រមោចស្បើរ មិនរស់ទេតើទុក្ខអន្តអញ
លង់លុះផល់ផុតរដូវមួយ ទុំព្រួយរំលឹកតែស្រឡាញ់
ឃើញអស់កូនគេមកខ្មីលខាញ់ ពាសពេញបូលវត្តសន្តត្រូវ ៗ

១- ប្អូប់ខ្វះប៉ា បើបានខ្លួនបងគិតឲ្យនៅយូរ គ្រាន់ជួយគិតគូរ . . . ។

មកបុណ្យមកបួសមកបិណ្ឌភ្ជុំ មកដល់ជំនុំជាច្រើនផ្លូវ
មកពប់បាតបូជាតម្រូវ តម្រង់ផ្លូវចេញវស្សា ៗ
នេនទុំទុក្ខធំឥតស្បើយ ទុក្ខហើយហៅពេជ្រមកប្រាប់ថា
នេនពេជ្របួនអើយចង់ឈឺផ្សា ដូច្នេះប្រាជ្ញាជានៅមិនបាន ៗ
នេនពេជ្រទទួលស្រួលសង់សប ជាទុំអើយជួបឲ្យផ្លូវក្សាន្ត ៗ
ទំកំពារពេលយើងប្រមាណ ចូលឋានលាគ្រូព្រះទ័យ ៗ
១៦០-នេនទាំងពីរពិតគិតល្ហោះស្រេច បែរគេចយកទៀនធូបធាប់ខ្វី
ដើរទៅបានដល់ទៀនកុដិ ដាក់អង្គគង់ខ្វីក្រោមបំផង ៗ
អុជទៀនអុជធូបក្រាបវន្ទា សូត្រចប់ចូលលាហើយសាសង
ជាសូមទានប្រោសគត់ទោសម្តង បំណងមកលាព្រះគុណធំ ៗ
លាចែកលាបាកសិក្ខាបទ សន្ទូតព្រះគុណប្រោសយើងខ្ញុំ
ទាំងពីរនាក់ទឹងថ្វាយបង្គំ សូមសុំករុណាត្រាប្រណី ៗ
ផ្សិតខ្ទួលផលមានគារធុរៈ ញាតិញោមដល់ថ្នាក់គាត់កើតអ្វី
រោគជួនទុរនមិនគប្បី ញោមស្រីដល់ស្រែបែរបេនថា ៗ
អង្គីរគេផ្លូវត្លូខ្មោចព្រៃ ដោយភ័យណាស់ហើយគាត់សម្លា
សំពះអស់ខ្មោចនៅវគ្គា បំណាំជូនតាមក្មិសេព្វ ៗ

www.elibraryofcambodia.org

១៦៩- គ្រោះថ្នាក់ជំពាក់ញោមស្រីបន់ ថាអន់ឲ្យខ្ញុំលាគ្រឡប់
សឹកទៅឲ្យជាស្បើយកុំថប់ ដួចចប់ដល់ចាស់ឈ្មោះចាំងព្រម ៗ
លោកគ្រូស្ដាប់ជាក់ក្ដោក់ក្ដារ ធ្មួនប្រូកលេខហាថាតែហោង
កុហកអញទេអាកញោម ស្រីតាមស្រួតពោលពោលមកលា
អញរាយលេខលប់គ្រប់ដើងហារ លេខឆ្លើយឡើងថាអាកំពារ
កុំពុះទម្ងុះក្រែងវេទនា ឃើញជាខេនពេជ្រគេចគ្រាន់បើៗ
ខេនពេជ្រសឹកចុះវែងបុស្សបាន ទុំឯងឈប់ទានទើបប្រសើរ
ចាំដល់ពិសាខសិនសឹមដើរ សឹកហើយត្រូវលើបានជាធំ ៗ
លន់លុះដល់ត្រូវរដូវវែង មិគសិរត្រូវខ្យល់ខ្វល់ជ្រញ្ញឹ
វេហើរហល់ដល់ខេនទុំ ក្រាបយំក្រំយល់អំពល់ពី ៗ
១៧០- ដំណើរមួយព្រួយប្រាណមិនបានសឹក មួយទៀតព្រួយនឹកចារនៅទី
នៅតាលត្បូងឃុំសមស្រីទី– កសប្អូនបានរេតទេដឹងអើយ ៗ
ខេនទុំខេនពេជ្រគេចបង្អិល ថាចាំថ្ងៃសីលក្រោយទៀតហើយ
យើងវេះតែលាណាពេជ្រអើយ ពេជ្រឆ្លើយថាកុំខឹមមិនបាន ៗ
ខេនទុំទុក្ខនឹកកើតទៀតប៉ុ ស្ដាយស្រីស្ដាយស្រស់ផ្ដស់គ្មានក្សាន្ត
អត់បាយចំណីស៊ុំមិនបាន គិតណាសមួយតានបានបីមាត់ ៗ

www.elibraryofcambodia.org

លន់លុះគម្រប់ចប់ជួបគ្នា    វេលាខែបុស្សព្យុះខ្យល់ផាត់
រហើយត្រជាក់ក្តាក់ត្រឹប្រាត់    ផាយផាត់ពពកមកដេរដាស ។
ដន្គោលដន្គំប្រជុំជិត    ងងឹតពេញស្ថានដានអាកាស
នេនតីរពន់ព្រិតគិតប្រឡាស    ប្រទៀសមិនឃ្លាសស្ដាសដានគេ ។
១៧៩-នេនពេជ្របូលលះពារប្រចុយ    គិតជាខុសអុយបើលោកដេរ
ទៀនទៅដល់ផាកអគ្គីកាយេ    លើកហត្ថទាំងទ្វេប្រណម្យនៅ ។
លោកគ្រូសាកសួរគួរវិញថា    ពេជ្រសឹកប៉ុណ្ណាក៏សឹកទៅ
កន្លែខបុស្សបានទទួលត្រូវ    សឹកបុះធ្វើស្រូវដូវស្រួល ។
នេនទុំសម្លំបបាំស្ដាប់    ពេជ្រគេសឹកធាប់បានទទួល
ព្រះបោះហើយទុំកុំអាក់អួល    ខ្ញាញ់ខ្នួលរំងឹរតជញ្ជឹងទាំ ។
រូបជាអញនៅមិនបានទៀយ    ព្រះគុណខ្ញុំអើយហេតុតែកម្ម
ជាកាលណាទឹងប្រឹងទ្រទ្រាំ    ម៉្ងៃសមស្ទាប់ខ្លួនមួនមែនពិត ។
មិនស្ដាយផ្លូវស្រុកណាបានប៉ុនសក់ កម្មនាំកញ្ចក់ឲ្យងងិត
មោហ៍បាំងផ្ញាំងគ្របក្របសោបរឹត    គ្មានគិតគ្មានគួរលោកគ្រូខ្ញាល់ ។
១៨០-នេនពេជ្រលាសឹកត្រឹកខេះទៅ    ទុំនោរគ្រៀមផ្អស់ស្ទុះទៅគាល់
បណ្ដោតពេជ្រឃាត់ថាកុំអាល    ទាំស្រាលព្រះទ័យភ័យប៉ុពេក ។

www.elibraryofcambodia.org

យើងស្ទេះទុំពេជ្រគេចសម្ដែង ស្រីទាវចំបែងរែងរិះរេត
កើតទុក្ខមួនមាំក្រិសញ្ញែក កែរក៏តែរឹងទន្ទឹងទុំ ៗ
ជាទុនអញស្ដាយក្រហាយប្រាណ មិនក្សាន្តចន់ខ្លួនប្រៀបហាក់ក្ដុំ
រលើងបត្តូតាផ្ការលំ សង្កត់សៀតក្រំរណ្ដំខាំង ៗ
ខ្លោចផ្សាក្ដៅក្ដួលខ្លួលក្ដឹងថ្លើម ផ្ដើមផុតៗ ស្ទុតកាន់កាំង
ម៉្លេះហើយលោកអើយប្អូនមរណ៍ ខ្លួនស៊ាំងស្គាំងស្គមទ្រមវេទនា ៗ
ពីដួចរួចអ្នកបាកពេលទៅ ទុកខ្ញុំប្អូននៅឲ្យកំព្រា
កំព្រានព្រួយប្រាណតុំបានជា ទាវពរកមើលព្រើលស្រមៃ ៗ
១៩៥-ហាក់ដូចពួសត្វចាប់ផល់ទុំ លោកស្ទ្រស្ដាប់ដុំណាអ្នកថ្លៃ
ស្វរស័ព្ទសម្លេងគួរគាល័យ ទាំងរូបប៉ប្រែប៉ប្រិមប្រែ ៗ
សប្បុរសយល់ចាប់ប្រដាប់ស្បង់ ត្រចង់ដូចវង្សព្រះច័ន្ទដែរ
ត្រចះក័ក្រមួលស្រួលដូចខែ · ដូចខាត់ផុសបែរជាបែកបាត់ ៗ
ជាបានប្រាណប្រុសមកវិញដែរ ប្ដូរមួយជាបែរដោយឈឺថ្កាត់
ភ្លើម្ដេចបានដឹងដំណឹងស្លាត់ ដួលគេឲ្យស្កាត់រង្គាត់គន់
មិនដឹងជាផ្លូវទៅត្រង់ណា ខ្លួនអើយខ្លោចផ្សាជាទុក្ខធ្ងន់
ពាប់ពៀបដូចទូកដូចទឹកជន់ ដោយទន់ដល់ទៀបហៀបក្សិណក្ស័យ

www.elibraryofcambodia.org

រួចចាប់ហៅទៅនាងនោះថា  នោះអើយជួយក៏ជួយកប់ដៃ
ជាយូរប្ដីឆាប់ដោយស្រមៃ  នោះស្មានខែថ្ងៃប៉ុន្មានមក ៗ
៤៩០- នាងនោះកំលៀងបញ្ចៀងឲ្យ  ថាចាំខែក្រោយមើលពពក
សាត់ពីទិសទីក្លៀសានជ្រក  ពពូនសមក្ពុកមកចារស្រី ៗ
ខ្យល់ផាត់ត្រជាក់ធ្លាក់សន្សើម  ជ្រួលជ្រើមក្នុងចិត្តគិតប្រណី
ប្រឹងនឹកមកចារបង់បេតី  ហេតុអ្វីប្រែដល់ទាល់ជាសង្ស័យ ៗ
សព្វថ្ងៃព្រួយដៃវៃគ្មានសុខ  ម្ល៉េះសឹងមិនលក់ត្បិតបោះបង់
វែរវែកត្បិតបានប្រាថ្នាផ្ដូង  សាងសីលស្មោះត្រង់តម្រង់កាយ ៗ
តម្រេកកុំគិតបង់ស្និទ្ធស្នេ-  ហាហេតុព្រោះតែខ្លួននៅឆ្ងាយ
មិនយូរប៉ុន្មានទេចារអាយ  លោកស្រាយសិក្ខាប្រាថ្នាជាក់ ៗ
កុំទុក្ខខ្វល់ញយំសុំឃាត់នាង  សមគេមិនរាងកុំផ្អើលភ្ញាក់
ក្រែងជាមិនជាកើតធុរៈ  ដឹងដល់ម្ដាយជាក់ដេរផ្កាសា ៗ
១៩៥- ថាកូនមិនសុទ្ធពុតដូចគោ  សន្ដានគេហៅគេសើចថា
កូនមានពូជពង្សមានវង្សា  ព្រោះឥតកិរិយាស្រើចវៃ ៗ
ហៅបងរំលឹកកុំនាងខឹង  បងនឹងខឹងទេណាថ្លៃ
នឹកធ្លាប់ដឹងចិត្តមកសព្វថ្ងៃ  វិស័យដូចពាក្យបុរាណថា ៗ

www.elibraryofcambodia.org

ធម្មជាតិជានំគេផ្គុំបាន　　ជាក់ក្នុងនាឡិបានតាមចិន្តា
មិនដែលទំធំលើសប៉ុនណា　　ទាវអើយបងមហាថប់ថែដួនៗ
ក្រែងគេមិនមករកទាវទេ　　ទាវប្អូនកុំជេរបងក្រែងជួន
រំលឹកទៅបុះក្រែងគ្រោះខ្លួន　　ត្បិតអ័ព្ទដួនគេកួនគុំ　ៗ
សមគេជាកូនចៅហ្វាយស្រុក　　បុណ្យគេធំស្តុកនាម៉ឺនជុំ
ឈរក្បែរខេត្តខាងត្បូងឃុំ　　ទុំពស្ត្រីទាំងផ្កាសដូចគេឯង ៗ
បងប្រាប់ទាវទៅពៅកុំអាក់　　កុំអន់ថ្នាំងថ្នាក់ចិត្តចំបែង
មិនបានប្រមាណទេទុំស្ងួន　　មកដល់មិនលែងកន្ទួងស្រាប់ៗ
ទាវឆ្លើយថាមែនដូចនោះថា　　នោះមានប្រាជ្ញាវៃចំណាប់
ថាត្រូវសមទុំមកដល់ឆាប់　　នោះប្រាប់ករព្រឹសលើសសព្វដងៗ
ដឹងហើយទាវស្បើយប្រាណបានតិច　　ប្រះប្រាណដេកផ្ងេចលក់ជាម្តង
លុះភ្ញាក់ព្រឹកប្រឹងរំពឹងបង　　អុជទៀនធូបផ្សងដល់នេនទុំ ៗ
ស្ទុះរៀងទាវទៀតឆ្ងៀតសម្តែង　　ដំណើរទុំតែងយកផាហ៊ុម
គ្រប់គ្រងកាយាពិដោរជុំ　　ក្រអូបពិតពុំមានរសាយ　ៗ
លុះជួបដួនយប់យន់ស្ងប់ស្ងាត់　　ព្រួចព្រឹប្រមាត់រន្ធត់កាយ
រន្ធត់ថែថប់ជ្រប់ខ្វល់ខ្វាយ　　មិនស្តាយចង់សឹកទឹកទាវស្រីៗ

www.elibraryofcambodia.org

២០៩- ព្រឹកព្រាងឡើងច្បាស់ព្រះសូរ្យសែង  ចាំងថែងពីបូព៌ារស្មី
បំបាយដល់អគ្គីពុំលង់ខ្មី  ទុំចុះដល់ដីដើរចេញទៅ ។
លង់លុះបានដល់សកលស្ថាន  ផ្ទះម្តាយទុំបានជួនជួបនៅ
ម្តាយសោកយំយល់កូនដល់ទៅ  ស្រែកអរហៅពៅចុះម្នីម្នា ។
មកពិតទូលថានេនបាបុត្រ  មន្តមកពីកុដិថ្មើរណេះណា
ចុះកូនពន្ធកមកនេះផា  ទុក្ខព្រួយវេទនាឬសុខសាន្ត ។
នេនទុំយំថែយកទឹកភ្នែកស្រក់  គិតកួតកុហកព្រោះម៉ែនក្សាន្ត
បំរើនពរញោមឆាន់មិនបាន  អាចក្តីប្រមាណប្រាណមិនស្រួលៗ
ទៀបឈឺក្លិនពោះលោះថ្ងៃតិច  ដូចគេខ្វារក្តិបស្ទានដូចមួល
ដូចមួត្រសំពោរក្តៅខ្លាញ់ខ្ទួល  រំជួលព្រឺព្រួចរួចខានសឹង ។
២១០- ទឹងឆ្អេចមិនលក់ទេញោមអើយ  ពូកកែបកល់កើយដេកស្ទក់ស្ទឹង
ប្រះប្រាណដល់ខ្ញុំយដំលើយរឹង  ដូចទឹងទំអត់សន្កត់ទុក្ខ ។
អាចក្តីជំណាលកាលថ្ងៃមុន  ឡើងលាព្រះគុណគ្មានមើលមុខ
ពិតថាមិនស្រួលមួលសៀតចុក  ថាខ្លួនមិនសុខមិនស្ទូវជា ។
លោកគ្មានបើកសោះបណ្តោះពេជ្រ  ឯងទូលដូចម្តេចលោកកំនើក
ឃាត់ទុកធ្វើក្លីឲ្យវេទនា  ញោមទៅបំពារលាឲ្យផង ។

www.elibraryofcambodia.org

មេម៉ាយម្ដាយខ្ញុំយំតាមកូន គាត់ក្រាបអង្គុះនះហើយសាសង
ថាម្ចាស់ម្ដាយអើយកូនសព្វផង មិនដែលមានហ្មងក្ដង់ទើនអ្វី ៗ
បោកប្រះប៉ះអារង់ណង់គេគាប់ ប្រគល់អស់ទ្រព្យមោះចាស់ថ្មី
ឲ្យម្ដាយចែប៉ាំស្លាហ្មារ ម្ដាយទឹកចំណីស៊ីតាមចិត្ត ៗ

១១៩.ចុះមានប៉ាំប៉ាគុម្មេចម្ដងណោះ ម្ដាយនែងត្រេកត្រេះគួរអាណិត
អាសូរកូនគួរស្មើជីវិត ឥឡូវខ្ញុំក្ងត់តនរណាផង ៗ
ពិត្តុបផល់ខ្ញុំដំម្ដេះហើយ កូនអើយម្ដាយត្រៃតដំណើង
ដំណាលទៅចុះក្រែងខុសផ្សេង បើម្ដឹងធ្វើម្ដេចស៊ីម្ដាយទៅ ៗ
នេនខ្ញុំព្ទម្ដាយសោយទុក្ខ ដូរអង្គដោយសុខសាន្តដោយនៅ
ដោយអ្នកម្ដាយស្រីគាត់ស្ពឹក្រៅ តាមតុំរុសខ្ញុំចប្រែខ្ញុំណា ៗ
ថាក្រោមអាបក្ដីមៀវត្ដបាន ក្រោមកេតៃប្រឹងម៉ានផាប់ម្ហូម
រួសរាន់ប្រញាប់កុំរេក ទានតាចក្ដីដាអន់អង្គព្រាណ ៗ
ហើយមួយស្ពានដួចខ្មោចដូនតា តែងនៅក្បែរតាំងប៉ុន្មាន
ដូរព្រះជួយផងបើមិនបាន ទៅណាត្រូវក្បាន្តស្រួលព្រះខ្ញុំយៗ

២២០.មេម៉ាយម្ដាយខ្ញុំដំណើងគិត យល់ដល់គំនិតហើយរៀ
លើកហត្ថាប៉ប់ម្ខុស្សាខ្ញុំ គៀនធួបយកស្បែរផណ្ដប់ដើរ ៗ

www.elibraryofcambodia.org

បាបុះល្ងតល្ងន់ស្រទន់ស្រប ទើបគាត់បង្គ្រាប់បួលទៅស៊ើ
ទឹងគ្រប់ស្បូត្រមួយអង្គគ្រាន់បើ ថាយើលោកម្ចាស់ខ្ញុំខ្មាសគេ ៗ
អ្នកផងអឹងកងទាំងក្មេងចាស់ គេសរសើរណាស់ឥឡូវប្រែ
ព្រះទ័យព្រះគុណមិនធ្ងន់ដែរ ថាលោកគ្រូកែគិតបទណា ៗ
ខេនខ្ញុំកូនខ្ញុំថ្វីលោកម្ចាស់ គាប់ណាស់ម្ដេចគួរលោកមេត្តា
កូនខ្ញុំទៅប្រាប់ដល់ម្ដាយថា ណាចាកសិក្ខាសញ្ញាកូន ៗ
ជាអកុសលតម្កល់ទុក មិនបានជាឈប់នៅសុខសួន្យ
ជាសាមណេរទេណាលោកប្អូន ដោយខ្លួនជាស្រីសេចក្ដីចាល់ ៗ
២២៥-ទើបនាងម្ដាយខ្ញុំបង្គំលា ចាកទីនោះណាលីលាដល់
ឡើងកុដិលោកគ្រូបង្គំគាល់ លើកហត្ថតម្កល់លើសិរសា ៗ
ហើយពិតថាខ្ញុំសូមក្រាបទូល បើគួរមិនគួរប្រោសករុណា
ប្រណើខ្លួនស្រីឥតសិកា(១) ចេះគួបារិនថាក់ចាផ្ទួស ៗ
ខេនខ្ញុំកូនខ្ញុំមន្តទៅដល់ ផ្ទះហើយមិនសល់ថាត្រាំផ្នួស
បង់ចាកសិក្ខាប្រាជ្ញាបួស នៅយូរក្រែងជ្រួសជ្រលួសលេង ៗ
ឲ្យខុសប្លោះឆ្លោយដោយខ្លួនពាល នៅស្រាលតម្រេកពេកទឹងល្បែង
ខ្ញុំម្ចាស់ព្រួយណាស់មួយគិតក្រែង បំបែកឈឺមួលមិនស្រួលខ្លួន ៗ

១- ច្បាប់ខ្ជះបាៈ ខ្ញុំជាសិកា ៗ

មែនឬព្រះគុណធ្ងន់ដូចថ្ម　ក្រែងឲ្យឆាន់ស្កទំចិនយួន
នោមយប់ថាស្ទះធ្នូរដោយដួន　ជុះយប់ដេកពួនពុំបានសោះ ។
២៣០-លោកគ្រូពុំយូរមានពុទ្ធដីកា　ថាទេសិកាទុំកម្លោះ
ណាទៅលក់គោកក៏ដាច់អស់　មកដល់ក្រៀមក្រោះស្រណោះស្រី
ខានខែត្រត្បូងឃុំក្រមុំច្រើន　ស្រៀបស្រស់ស្រវើនក្មេងលីថ្មី
ឥឡូវចបើងចង់បានប្តី　ហេតុហ្នឹងអាចក្តីយល់ពុំគាប់ ។
ពុំគួរបណ្តោយឲ្យសឹកទៅ　ភយលេខឃើញត្រូវពានលើឆាប់
ខ្ញុំនាយនេនខ្ញុំថាអក័ព្វ　ឃាត់ដាច់ខំរាំដាច់ឆ្នាំហ្នឹង
នាងជាមេម៉ាយម្តាយនេនខ្ញុំ　ស្តាប់លោកគ្រូធំគន់សម្ងឹង
សម្លក់មកគាត់ឃាត់តែរើង　ពុទ្ធដីកាក្រញឹងដូចខឹងខ្លាំង ។
រូបគាត់ណាចុះមកដល់ដី　ថាកូនពីសីកុំតតាំង
ទល់តបធ្វើម្តេចប្រៀបដូចចំប្លាង　ត្រូវដូចបាកំងគាងកាំភ្លើង ។
២៣៩-តែលោកបាញ់បាត់មិនបាត់ស័ក្តិ ទៅត្រូវសត្វស្លាប់ដូចខ្ទុនយើង
បើលោកតាយថាផ្គាររលើង　រលំបាក់ដើងដួលដល់ស្លាប់ ។
ហេតុនោះឈប់ទៅប្អូនម្តាយ　បើក្តៅក្រហាយកូនក្រឡាប់
ក្រឡេករកទឹកផឹកលុបឆាប់　ស្រន់ស្រស់រូបជាប់ជារសេរសេរ ។

www.elibraryofcambodia.org

រៀនសូត្រធម៌គាថាធ្វើការអ្វី ចរចេញពីក្ដីទើបបិតចេរ
ប្រៀបដូចសំពត់រហែករេរ ប៉ាក់ផ្ការៀបចំចំពោសហាន ។
ទើបនេនខ្ញុំឆ្លើយថាណ្ហើយឈប់ ញោមកុំប្រៀបសព្វទប់មិនបាន
អញ្ជើញទៅផ្ទះប្រុះសម្រាន្ត ញោមទ្រាំកំសាន្តកុំសោយសោក ។
ចាំមើលដល់ព្រឹកនឹកថ្វីខ្ញុំ យកតែផាហ៊ុមតាវឲ្យមក
ដើរទៅចូលព្រៃប្រាស័យជ្រក ស្ងាត់ហើយខ្ញុំក្រោកឈរវន្ទា ។
២៤០-ថ្វាយបង្គំព្រះសំពះគ្រូ ផ្លាស់ស្បង់ពុំយូររួចលីលា
សឹមចរចូលទៅក្នុងព្រះវិហារ ស្នាលាទោសទុក្ខមុខជាបាប(១) ។
នេនខ្ញុំជំនុំតែនឹងម្ដាយ ក្រហាយក្នុងខ្លួនដូចឈឺដាប
ឈឺហ្នឹងឈឺចិត្តផ្គិតមិនសាប សូមក្រាបលាកលាឃ្លាឃ្លាតហើយ
ព្រះគុណថ្លៃខ្ញុំកុំប្រកាន់ កុំយកទោសធាន់ករុណាឡើយ
សូមស្នោះពិតស្នោះដោះឲ្យស្បើយ ដប់ក្រោយផុតទុក្ខទៅមុខទៀត ។
នេនខ្ញុំគិតស្រេចគេចស្នោះក្ទឹង ម្នាម្នះដោយខឹងលះស្ងន់ស្ងៀត
ចាប់យកសំពត់ផ្ទត់វេចសៀត កណ្ដៀតដើរដល់យល់ព្រៃធំ ។
សូមសួនពួនជ្រកយកបណ្ដា ក្ដីផ្កាទៀនធូបចំណីនំ
បូជាទេវាស្រេចនេនខ្ញុំ ផ្គងផ្គុំលើកហត្ថប្រណិប័តន៍ថ្វាយ ។

---

១- ច្បាប់ខ្លះថា ៖ ចូលព្រះវិហារ ហើយស្នាណាទោសទុក្ខនានាដែលជាបាប ។

www.elibraryofcambodia.org

២៤៩-សូត្រថាឱកាសសក្តេ កាមំកាមេនៅដែនកាយ

ចរូបេប៉ន់បំណាន់កាយ គិរិសឹកស្រាយមិនស្តាយសោះៗ

វន្ទាវន្ទៈអ្នកកុំឃាត់ ផ្លាស់ស្បង់ពេលម៉ត់មិនស្រណោះ

រូបសៀកសំពត់ហូលល្អស្រស់ លើកអស់អង្គ្រែកដាក់ទុកទើរ ៗ

ព្រឹក្សាប្រគាបទាបដិតដី បណ្ឌិតទុំថ្មីគាត់ហ៊ានធ្វើ

សឹកស្រេចបរត្រាច់ដើរលេលើ អំពើពុតខូចមិនរួចខ្លួន ៗ

ដើរដល់សាកលបាន់បន្តិច វេះវាង់រកពេជ្រស្រេចជួបជួន

បណ្ឌិតពេជ្រសើចហើយជ្រកពួន ទុំចាប់អន្ទ្រូនអន្ទ្រន់លេង ៗ

គ្រានោះពុំលន់រង់យូរថ្ងៃ ទុំទឹកអាល័យទាវហើយល្ហើង

ជ្រួលជ្រប់ស្រយុតស្ងួតរង្វេង ទឹកណាស់កន្វេងកន្វែងផែល ៗ

២៥០-ស្រមៃដូចហាក់ភ្ញាក់ប្រាំ· តាប់ដៃសិកាថាប្រហែល

ដូចទាវនាងសាវធំគ្រាន់ក្រៃល ដំណៃលដំណើរទេណាំស្រី ៗ

ស្រណោះស្រស់ខ្លួនស្ងួនស្តាប់បង់ សូត្រឲ្យអ្នកផងញាតិនៅដី

នៅដែនត្បូងឃុំជុំថ្មី ១ មិនមានក្តេចក្តីសិទ្ធស្នេហា ៗ

បណ្ឌិតទុំទើបនឹងសឹកថ្មី ប្រាប់ពេជ្រថារុំពេជ្រខ្ញុំថា

ឲ្យប្អូនអាណេតផ្សេតបេក្ខា ចិន្តាប៉ុនប៉ង់បំណាន់ទឹក ៗ

www.elibraryofcambodia.org

ក្អកដល់ស្រីតាវនាវទុកស្រាប់ បានឲ្យថ្នាប់ទើបលើក
សម្ពត់ជាហ៊ុមផ្អិកក្អិនក្អឹក រាល់ពេលយប់ព្រឹកទាន់សឹកហើយ ។
បណ្ឌិតពេទ្យប្រុងរង់ចាំស្ដាប់ ឆ្លើយថាទាប់[1]មែនខុំអើយ
បើហ្នះខុំដើរពុំទាន់ស្បើយ ទៅទៀយព្រោះខ្លួនមួនមិនសុខ ។
២២៩-នៅពោសត្សិតអើងមានថ្នាក់ ព្រោះបួសដៀងជាក់ជាកុលបុត្រ
គ្មានដឿព្រះគុណធ្ងន់បំផុត ហ៊ានតែទៅសឹកមិននឹកស្ដាយ ។
ខុំជាបើហ្នះពេទ្យជួនទៅ យើងរកគ្រឿងគ្រាំគោដទ័ទាំងឡាយ
ប្រគេនលោកគ្រូលាទោសស្រាយ ទើបបាត់គ្រហាយក្នុងព្រះទ័យ ។
បណ្ឌិតពីពិតគិតឃើញស្រេច ចរត្រាប់ទៅផ្ទះរួសកន់រៃ
រកអស់គោផ្សផលផ្លែឈើព្រៃ បានស្រេចខុំស្ដីពេទ្យជួនដល់ ។
បួលដល់ក្នុងឋានបានឡើងកុដិ លោកគ្រូគន់ផ្គត់ផ្អែកខ្នើយខ្នល់
ខុំពេទ្យជាក់អង្គលើកករកល់ ក្អុំក្អិត[2]ផ្អឹមផ្អាល់លើសិរសា ។
លោកគ្រូឆ្ងៀងក័ក្រូជាក់ប្រាកដ ជាខុំកម្សត់មកមានការ
រកអញថ្ងៃទៀតមារយាទអា ណ្ហើយចុះមិនថាធម្មតាសង្ឃ ។
២៦០.មិនដែលគ្រូណាផ្ដាសាសព្ទ មិនមានខឹងស្អប់លោកស្មោះត្រង់
បើសិស្សរើលល្អៀងផ្អៀងតម្រង់ តម្រែកក្នុងអង្គប្រុងប្រយ៉ៅ ។

---

១- ច្បាប់ខ្លះថា: ឆ្លើយតាប់ថាអើ ៗ ២- ច្បាប់ខ្លះថា: ផ្តុំដៃ ៗ

www.elibraryofcambodia.org

ឲ្យកើតកេរ្តិ៍យសខ្ពស់ត្រដាប បើសិស្សណាខ្ជាចហើយល្ងង់ទៀត
លោកប្រឹងបង្ហាត់កុំឲ្យនៅ រកហៅរៀនសូត្រហូតបេះ ។
ពេជ្ញទុំប្រណាម្យក្រាបស្ដាប់គ្រូ ប្រដៅគ្រប់ផ្លូវនៅកកេះ
ក្រុបកដកកអៀនស្រមេះ ប្រុងរិះឆ្លើយឆ្លងសនិពុទ្ធដីកា ។
សូមទានយើងខ្ញុំសុំទោសទុក្ខ ប្រោសប្រាណទៅមុខទ្រង់ករុណា
ព្រះគុណអត់អស់ទូវទោសា មេត្តាគង់កើតស្នេហ៍រៀងទៅ ។
ខ្លួនខ្ញុំខុសឆ្គងហ្មង់ម្ដេចក្ដី សូមសុំព្រះទ័យប្រោសឲ្យនៅ
ជាសិស្សព្រះគុណទុកជាខ្លៅ ដោយក្ដៅតណ្ហាសង្ព្រាសត្វ ។
២៦៩–លោកគ្រូមានពុទ្ធដីកាឆ្លើយ ថាអើម៉ែនះហើយដូចឯងកាត់
ស្ដីនោះចំពោះត្រូវពេញមាត់ ប៉ុន្តែប្រយ័ត្នផ្ទាត់ផលខ្លួន ។
អញអត់ទាំងអស់ទោសចាស់ថ្មី កន្ទោះលោកិយកុំឲ្យជួន
ទុក្ខពីមុនមកទឹងជ្រកពួន មិនរួចត្បិតក្បួនច្បាប់ប្រាប់ច្បាស់
ព្រះអង្គសម្ដែងតែងមានទុក្ខ កម្មណាប្រែជាសុខរៀងផលចាស់
ឯថ្នាក់មរណំតាំងស្រឡះ(១) ព្រះពុទ្ធដីកាព្រះត្រាស់ទេសនា ។
បណ្ឌិតពេជ្ញទុំបង្គំទៅ ចាំស្ដាប់ប្រដៅព្រះពុទ្ធដីកា
លោកគ្រូអាណិតសិស្សសូត្រថា ភគ្គាវត្ថុ បទទាំងបី ។

---
១- ច្បាប់ខ្លះថា ក្រែលក្រាស់ ។

www.elibraryofcambodia.org

តព្រះជាម្ចាស់ទុកខ្លួនទាន សត្វណាស្រែកឃ្លានទាំងប្រុសស្រី
ធម្មតាកើតមកក្នុងលោកិយ សូស្ដីមង្គលយល់ស្រាប់ហើយ ។
២៧០-ពេជ្រទុំប្រណម្យស្ដាប់លោកគ្រូ សូត្រជប់ឲ្យពរទទួលឆ្លើយ
ថាសាធុសូមឲ្យបានស្បើយ ល្ហែល្ហើយដូចពរអរទទួល ។
លើកហត្ថប្រណិបតន៍ផ្គុំតាំងសង ក្នុងចិត្តប៉ុនប៉ងត្រូវទំនួល
ដំណើរលើខ្នងត្រកូល ស្រាកស្រួលព្រឹសព្រឺធ្វើហាក់ភាយ ។
ទើបទូលលាលោកថាសូមសុំ ព្រះគុណប្រោសខ្ញុំត្បិតនិយាយ
ទឹងអស់បាសកនៅស្រុកឆាយ រួចកយកល់គ្នាថាឲ្យទៅ ។
សន្ធតប្រាកដមិនឲ្យខាន សន្ដានផ្ដាំនោះចំពោះត្រូវ
ប្រមាណបណ្ដាក់គោកផាស្រូវ អនិះទៅក្រែងខុសអស់សញ្ញា ។
បាសកត្បូងឃុំទទឹងថ្ងៃ ពួនពឹងអាស្រ័យព្រៃបន្ទា
នូវបន្តអាគមវិជ្ជាការ(១) ខ្លាចព្រាយអ្នកតាគោបាឆ្លប់ ។
២៧៥-ហើយមានតម្រិះពេះសុខុម កគិតផ្សំផ្គុំទុំឲ្យឈប់
ផ្គងខឹងទានទាវទើបចូលម្ហូប យើងខ្ញុំដូចស្កុបវេះវាងមក ។
លោកគ្រូផ្គងស្ដាប់ស័ព្ទទុំពេជ្រ ឆ្លើយគេបកថាឯងគិតក្អក(២)
មិនមែនទេតើអាកំព្រក ធម្មតាទុក្ខសោកសព្វបណ្ដា ។

---

១- ច្បាប់ខ្លះថា: គេមានអាគមមន្តគាថា ។ ២- ច្បាប់ខ្លះថា: ឆ្លើយគេបកថាឯងលៃលក។

www.elibraryofcambodia.org

មនុស្សក្នុងលោកិយទាំងស្រីប្រុស មិនដែលស្អប់អស់ស្រីទេណា៎
កុំភូតកុហកអញដឹងការណ៍ ប៉ុន្តែមិនថាដូចផ្ចាញ់ផ្ចាល់ ។
ហើយឯលោកគ្រូគួរគិតឲ្យ បណ្ដាយតាមចិត្តមិនមានសល់
ថាអាទៅចុះកុំខ្វាយខ្វល់ ខ្លួនទាល់ស្គាល់គេឲ្យថេរលង់ ។
កុំអាងប្រាជ្ញាក្លាគ្មានគោត ខ្លាចគេចាក់ដោតព្រោះខ្លួនផុង
ស្រដីមិនៈកោតគេពួតព- ង្វាវតារគេគង់ប្រុងកិរិយា ។
២៨០-កុំអាទាហានពនទីទៅ ជំបួចកូនចៅគេផ្ដាសា
ប្រពន្ធគេធំកុំបើយអា ប៉ុនប៉ងប្រាថ្នាស្រវាចាប់ ។
ប្រកៀកប្រកាន់កំណាន់ទឹង ធម្មតាស្រីងើបធំដោយឆាប់
វាកេកក្មោះថ្ងោះបំណាច់ ប្រញាប់ទាន់ចិត្តឥតគិតក្រែង ។
ដំណាលដំនៀលដល់មកគ្រូ អង្គព្រះសព្វញ្ញូទ្រង់សម្ដែង
ថាបាបដកបដាច់សន្ដែង ផុតលែងកបកើតកំណើតទៀត ។
ឯអញគ្រូឯងឥតទោសា មិនប្រកាន់ថាអញបង្អៀត
អញឲ្យពរអ្នកចូរបែរបៀត មកគ្រូទឹងភ្លៀតសម្ដែងធម៌ ។
លោកគ្រូកាន់ផ្ចិតចិទព្រះភក្ត្រ សូត្របានព្ជាក់ឲ្យត្រេកអរ
អាយុវណ្ណំសុខៈស្មោះសរ សុំឲ្យបរិបូណ៌បានបុណ្យ ។

www.elibraryofcambodia.org

ពេលាពលំទាំងពីរនាក់ ឲ្យមានយសសក្តិប្រាក់ទ្រព្យធន
កម្លាំងប្រាជ្ញាមិនគាប់គន់ ប្រពន្ធក្រមុំព្រហ្មចារី ។
កេរ្តិ៍ឈ្មោះល្បីល្បាយសាយអំណាច អ្នកផងគោរពខ្លាចទាំងប្រុសស្រី
នៅប៉ុះព្យាបាលទាំងទឹកដី ស្រុកស្រីតារនៅទៅឲ្យបាន ។
កូនសិស្សបណ្ឌិតពិតពីរពេញ អម្ចេញពេញម្នះអស់ពីប្រាណ
ឥតអ្វីយកមកប្រៀបប្រមាណ ស្មោះស្មើដូចបានស្ថានសួគ៌ា ។
ស្រេចហើយបណ្ឌិតក្រាបស្តាប់គ្រូ លោកគ្រូឲ្យពរអភិវាទ(១)
អភិវាទលើកហត្ថបង្គំលា ចរចុះម្នីម្នាដើរចេញទៅ ។
ទៀតដល់លើផ្ទះដាក់អង្គកាយ ស្រដីប្រាប់ម្តាយថាឥឡូវ
អ្នកម៉ែយើងនេះសន្ទុតត្រូវ ដោយនូវដំណើរតើអ្នកម្តាយ ។
១៩០· ដាបើកឲ្យកូនប្តូអ្នកឃាត់ ត្បិតជួបសន្ទុះយើងឯណាយ
គេថាបើបានសុខកង្គកាយ សប្បាយជាធាថាឲ្យទៅ ។
ម្តាយអ្នកបណ្ឌិតគិតបង់ឃាត់ ទើបគាត់ស្រដីថាកូនពៅ
ម្តាយនេះសព្វថ្ងៃដូចមិនសូរ សុខសាន្តដោយនូវត្រូវកេតា ។
ពាសខ្លួនដូចដល់កុសលត្រូវ ទឹងពឹងរកហៅញាតិផងគ្នា
មិនដឹងជាកូនស្ងួនពុំអ៊ា ម្តាយទឹងកំពឹងកពេលាបាន ។

១- ច្បាប់ខ្ទះបិរ គ្រូពីអង្គ ។

ថាកូនប្រាកដសន្មតត្រូវ អ្នកខឹងចេញទៅទឹងឈប់ខាន
រាប់ផង់នាទីពីបុកណា កូនស្មានប្រយ័ត្នណា៎ថ្ងៃម្តាយៗ
ទើបឯបណ្ឌិតគិតពីប្រាណ អរព្រានជួបគ្នាទាំងពីរកាយ
ស្មោះសរស្រែកអរពេកអស្សាយ ក្រហាយដូចម្តេចក៏គេចហើយៗ
២៩៩ បណ្ឌិតពេជ្រទុំជំនុំគ្នា បែរភ្នានិយាយផ្លាស់ខ្លួនឆ្លើយ
ថាយើងទៅដើរសម្លាញ់អើយ ពេលពន់នៅឡើយមិនទាន់គេៗ
ធ្វើមាណាដើរបានប្រាណមានជ័យ មានលាភគ្មានភ័យពេលាជោគ
សិរីទ្ធិហោរតាមលោក ទាំងពួងវែងបូកយកស្លោកសូន្យៗ
កាកបាទមិនស្អាតខាតទ្រព្យ ចេញដើរខុសពារវេទនាខ្លួន
ដើរត្រូវសូន្យពីរប្តូរសូន្យបួន ចរជួនលាភៈជាក់ប្រាកដ ៗ
បណ្ឌិតពីរពេញស្រឡាញ់ពេល ប្រហែលចេញដើរដោយសន្មត
ពេលព្រឹកក្អឹកស្វាងបំព្រាងព្រាត់ ទើបគាត់ទាំងពីរលើលាចេញ ៗ
បាកចរជួបផ្លូវត្រូវកាលស្រែ យល់ញាតិដើរបែហាក់វិលវិញ
តំនាប់សន្តានទាំងពួងមិញ មីងមាថាអញខ្ញុំប្រណិប័តន៍
៣០០ ក្រាបលាពល់គ្នាទៅត្បូងឃុំ មីងអើយកុំយំខ្ញុំមិនគាត់
ពោលស្រុកក្លមិស្មានទៅលប់ហ្នាត់ មីងមាកុំផាត់ទាត់ម្តាយខ្ញុំ ៗ

www.elibraryofcambodia.org

អាណិតគាត់ផងបងប្អូនស្រោប់ តាមដោយសណ្តាប់ជួយថែទាំ
ក្រែងមានធុរៈកែគមកផ្សំ ក្រាលក្រំពុកញាត់ហត់ហឹតហៀរ ៗ
សន្តានខ្ញុំពេជ្រគេចធ្វងធ្ងើយ ថាអើយក្មួយមុខអង្រួន់ខៀវ
បែរទៅកពេញពាក់វិលវិលរៀវ ទុក្ខពាវដូចទឹកទិកដល់ខ្ញុំ ៗ
ទើបឯបណ្ឌិតតាំលីលា ធ្លាក់ដល់មាតាស្រុកត្បូងឃ្មុំ
ដើរហើយអស់អែកទឹកភូមិឃុំ ពេជ្រខ្ញុំរិះរៃងបម្បែងចិត្ត ៗ
ទើបខ្ញុំដល់ជ្រំឈើរបោះ ទឹកដើមស្រណោះធ្លុលធ្លែតធ្លិត
ស្រក់ស្រោកទឹកភ្នែកទឹកនោមស្ងួត ពារអើយបង់គិតឥតឧបមា ៗ
៣០៥-មកដល់វាលរៃងក្រែងដួលដុះ ផ្កាសត្រសុសផ្ទេកភ្ញីថ្នា
ដូចរូបសម្បូរពណ៌គន្ធា ដូចផ្កាក្រែងត្រស់ស្រណោះពេក ៗ
មៀងមើលទឹកជ្រោះស្មៅត្រកៀក ចិត្តបងបង្អៀតរំងិរំរេក
ត្រកួនដូចខ្លួនបងឈប់ដេក ឈប់ដោយម្ចប់មែកត្រែបែកព្រៃ ៗ
យាប្តូងដូចបងក្ងាត់ឃ្លាតឆ្ងាយ ព្រៃព្រួយមកអាយយូរឃ្លាតឃ្មែ
ស្រណេះស្រណ្តូតរហូតរៃ ម្ល៉េះសមប្អូនភ័យមមៃគិត ៗ
ហើយឥកពីរប្រាណបានដល់ព្រៃ ដល់ព្រឹករំពៃព្រួយរំងិត
ខ្ញុំពប់ដើមឈើប្រើបណ្ឌិត ពេជ្រឲ្យឈានយឹតត្បិតស្រកឃ្លាន ៗ

www.elibraryofcambodia.org

បេះផលពិសីសុំពិសា    ទុំនឹកដើមថាពេជ្រអើយមាន
ផ្លែព្លបដូចពេលតាវនាងហ៊ាន    នាងហាក់ដូចមានចិត្តចេតនា ។
៣១០-មើលមានផ្លែចន្ទន៍សិរមាន់ព្រៃ    ដូចតាវស្រីឈ្មេងទឹកសន្សារ
សន្សំយស្រមៃមិនបានថា    ដូចចន្ទផលាផុតពាកឆ្ងាយ ។
ស្រគំស្រគត់រលត់ធាតុ    ព្រួសព្រើលមារយាទមើលយល់ស្វាយ
យល់ស្វាតាំងហ្វូងលោតប្រញាយ    ព្រោះញាតិនៅឆ្ងាយតាយសម្ដីៗ
សម្ដែងកាពាថាប្រាកដ    នាវនាងតាវបទបានហេតុអ្វី
ផាបងឃ្លាឃ្លាតសន្ទាតខ្ទី    គោគេវិលវៃបែរបែកបង់ ។
បងមើលមានផ្លែឈើទុំខ្ទី    ស្វាយព្រៃស្វាយព្រាតដូចឃ្លាតស-
ន្សារសាប់បរគ្រាប់ស្មោះតម្រង់    តម្រេកក្នុងអង្គផ្ងង់មិនក្អេប ។
បងមើលគុយគាប់ប្រផាប់ផ្លែ    ប្រៀបដូចតាវស្នេហ៍មិនបែរគេច
របស់បញ្ចាំផ្កាទុំពេជ្រ    ឥឡូវបែរគ្រាប់មិនលេចព្រៃ ។
៣១៥ នៅឆ្ងាយរាលរៃនឹងបម្រុងចិត្ត    បំផាបងគិតត្បិតសត្វរៃ
សត្វរំតៃតែយំទុំមមៃ    មមាលឧទ័យថ្ងៃល្ងាចហើយ ។
ល្ងាចហួសជ្រលជ្រួសរន្ធងផ្លូវ    ដើរពានត្រង់ត្រូវប្តូរនៅឡើយ
នៅលង់ក្នុងព្រៃព្រឹក្សជ្រអើយ    រកជួបផ្អែកអើយលំហើយខ្លួន

www.elibraryofcambodia.org

ពេជ្រឆ្លើយថាអើបើដូច្នោះ　យើងរកចន្លោះណាមាំមួន
ប្រយ័ត្នក្រែងមានខ្លាក្រាបពួន　ខាំខ្លួនអសារដើតផង្ហជាតិ ។
ដើរមកឈប់ជ្រកពុំគប្បី　ព្រោះស្រីព្រួចស្រើបទើបឧហាត
ពេជ្រទុំជុំទុំកគិតស្មាត　ឡើងចង្អូរតាតឃ្លាតខិតខំ ។
លុះឡើងដល់មែកល្អមដេកបាន　ប្រះប្រាណមិនមានព្រួយបារម្ភ
ឮសូរសត្វយំទុំសម្ងំ　រៀបចំប្រុងប្រាណប្រមាណពេល ។

៣២០-ក្រឡេកក្រលៀងឆ្មៀងមើលព្រះ　ចន្ទចែងក្លឹបឡាស់រះប្រហែល
ម៉ោង១០យន់យប់យូរជ្រៅក្រៃល　ទឹកដៃលទឹកដល់ស្រងិលរងោក ។
ព្រះញាយផាយផាតស្វាតត្រជាក់　រហើយដល់ផ្កាក់សន្សើមស្រោក
ស្រប់ស្រស់ចុះចំបំព្រំជោក　ផាប់ផាំដើមផ្កាតន្លោកបង ។
សូរសព្ទសព្ទសត្វស្រណោះយំ　ឆ្លើយគ្នាទឹមទុំព្រលើយល្វើង
បណ្តិតពេជ្រទុំបារម្ភក្រែង　ព្រួយព្រឹសផ្ទែងចំបែងបង់ ។
ជានុយើងអើយមិនគប្បី　ដើរដេកក្នុងព្រៃព្រួយព្រោះស.
ឆ្ងាវសត្វពន្ធព័ទ្ធកល់រូបអង្គ　តម្រង់តម្រូវមិនត្រូវច្បាប់ ។
ប្រសិនខ្លួនក្តស់រស់ត្រដួច　ប្រសិនបើខ្ញុំខុសសណ្តាប់
មានពាក្យជំនៀលដៀលអឹងអាប់　ស្ទើស្លាប់ព្រោះស្រីអប្រិយប្រាណ ។

www.elibraryofcambodia.org

៣២៩ ណាព្រាយលោកគ្រូយូរពេលជ្រាប ថាឯងនឹងតូចទាបផៅសន្តាន
ថាសិស្សគ្រាន់បើលោកកប់អាន ឲ្យពរស្មោះស្មានក្សាន្តព្រះទ័យៗ
ផលលោកជ្រាបការថាឯងព្រើល នឹងលើលដើរដេកដោយដងព្រៃ
ស្លាប់ខ្លួនអសារក្តុំពនាល័យ ព្រះគុណទីនឹកភ័យស្តាយស្រណោះៗ
គ្រាទោះគ្រោះផារវេលាយប់ ភ្ញីស្វាងមើលគ្រប់ឃើញប្រណោះ
ល្អមចរចាកបេរលើលាផោះ ដើរចេញចាកចុះមកដល់ដី ៗ
ខ្ញុំពេជ្រគេចយល់សកលហាន លួមស្មានដល់កូមិផ្ទះពីរបី
ចរចូលកេសុំបាយចណ ស៊ីផ្លែតដូចក៏ចិត្តបេតនា ៗ
ស្រេចហើយចេញចាកលាកលោកទៅ កាត់ដើរសំដៅយល់ចក្បា
បក្សីឈ្មោលញីទាំងគ្រា ខ្ញុំមានកចាសាកសួរពេជ្រ ៗ
៣៣០. ថាសួនមើលសត្វប្រាក់ខ្ញុំ មៀមមុំវីខ្ញុំយហើរលេច
លលកហើរជ្រកដើមព្រៃស្រែច ពពេចហើរគេចដើមពពួល ៗ
សេកយំខ្ញុំនៃដំបបែងគិត ដល់ទាវជោះសុំខ្ញុំមិនមិត្រមូល
មិនមានផលទៅទាវនានាចូល ចិត្តចាំអនុកូលប្ដូរទៅសោះ ៗ
ដូចនុករតើពេទនីទាំងដើរ ស្ងៀមព្រាយដំណើរប្រឹងផ្លូវផ្លោះ
ទៅផុលទាវយល់គ្នានស្រណោះ ក្រៀមក្រោះអស់មានទេដឹងអើយៗ

www.elibraryofcambodia.org

ដើរទៅពីទិសនោះដ្ដោះដល់ ដែនដីថ្នាក់ថ្នល់ជិតបង្កើយ
ក្រឡេកយល់ក្មេងហៅមិនឆ្លើយ អន្ទះហើយណាស់ទីនស្ដី ។
រាន្ទូរគួតខទាំងប៉ុន្មាន រូបប្រាណធុំក្លិនអាចម៍គ្រប់
ទុំពេជ្រនិយាយថារ៉េយរុំ អាឯងកុំភ័យទីនអ៊ូឡើយ ។
៣៣៩-យើងបន់ស្រួលអាឲ្យលុយគាត់ កុំឲ្យសល់ម្នាក់ថាឲ្យហើយ
ឲ្យហ៊ានទាំងអស់ប្រុងចាំឆ្លើយ ក្មេងអើយអញសួរគួរឯងប្រាប់ ។
ក្មេងផងហើយហាថាសួរម្ដេច បើបង់ដឹងកិច្ចគួរដោយច្បាប់
ដោយច្បាស់សុខចិត្តតាមសណ្ដាប់ គិតខ្លាចផងសំពួចាប់សម្ដី ។
ទុំពេជ្រឈោលេចមានវាចា ថាបើអាក៉ាយើងគប្បី
ឯផ្ទះនាងទាវល្អប្រិមប្រិយ ឆ្ងាយណាស់ពិសារទើបដើរដល់ ។
ទាវមានប្ដីហើយប្ដូរទេនាង ប្រាប់បងកុំរាំងពិតតាមស្គាល់
ឲ្យអស់ស្មោះត្រង់តាមយោបល់ ប្ដូលីរទេទាល់សល់ទទេ ។
ក្មេងផងសាសង៍ប្រាប់វិញជាក់ ផ្ទះទាវបើស្នាក់នៅមានគេ
តែឆ្ងាយប្រមាណព្រះសុរិយេ ទាបទន់ជ្រៀតជ្រែទើបទៅដល់ ។
៣៤០-គាត់មានតែម្ដាយមេម៉ាយស្អាត មានខ្ញុំសង្វាតខាងកុសល
ចិត្តជាអ្នកធម៌ផ្ដើមគ្គផល តម្កល់ចិត្តជឿដើរទៅឆ្ងាយ ។

www.elibraryofcambodia.org

ទុកទារជាកូនឲ្យចាំនេរ ចាំផ្ទះបិតបេរតែរៀងកាយ
នៅទីនក៏លៀងលេងលែងខាយ សប្បាយសងសារ៉ានមិនមានហ្មង ៗ
អើយើងផ្ញោចសភាពពិត ជាញាតិឆ្ងាយជិតប្អូនគបង
មេត្តាប្រាប់ណា៎ឲ្យដឹងផង បំណាងចង់ជាក់កុំអាក់អន់ ៗ
ចាំប្រាប់ទៅក្មេងលេងសម្ដី ថាអើងង៉ីយើងមកបន់
ល្បីទៅថាទារចេះចាំស្គន់ ផ្លាំស្គរគ្រេបកូនគមប្រមេះ ៗ
ទើបអ្នកតារប្រាណបានពួស័ក្ដ ក្មេងផងប្រាយប្រាប់ដោយសំណេះ
ចិស្រុតដល់ក្បិមចាំពេជ្ររះ ថានេះប្អូនម្ដេចពេជ្រផ្ទះទាវ ៗ
៣៨៥-ពេជ្រឆ្លើយចាំអើយកុំបារម្ភ កុំស្រេបង្អឺក្រែងអ្នកក្រៅ
គេចិងប្រកាន់វង្សព្រោះព្រាវ រកផ្ទះដែលនាវនាងទាវទុក ៗ
ត្បិតកាលយើងមកគាត់កប់ការ ម្ដាយធម៌ម្ដាយអាចថាចាំទុក
សមគេសម្គាល់ចំណាំមុខ ចិស្សុខយើងសេពអែបរកគ្នេរ ៗ
និយាយគ្នាស្រេចបាចចំដើរ តើបានអ្នកបើរចាំរេះរេរ
មិនហ៊ានស៊ើបសួរខ្វាចះណាដេរ រិះរកបែរយល់ស្គាល់មិនជាក់ ៗ
ទើបចាំលើកហត្ថប្រណិប័តនស្វរ ជាគួរមិនគួរសូមទានអ្នក
ផ្ទះហ្ន៎ម្ដាយធម៌ខ្ញុំកុំលាក់ ខ្ញុំឆ្លាប់ពីងពាក់សំណាក់នៅ ៗ

www.elibraryofcambodia.org

ទើបអស់អ្នកផងសារសងឆ្លើយ ថាអើមែនហើយចូលតាមផ្លូវ
ឆ្មាប្រកបរបងកន្ទងត្រូវ រួចទៅដល់ផ្ទះច្បាស់មែនហើយ ។
៣៤០-បណ្ឌិតទាំងពីរលើលាដល់ មើលស្គាល់ប្រាកដពុំលង់ឡើយ
ហាហៅម្តាយធម៌អរឆ្លាស់ឆ្លើយ កូនអើយបាត់យូរក្រមកដល់ ។
ទុំពេជ្រអរស្រេចគេចឡើងផ្ទះ លើកដៃសំពះឱនកាយគល់
នាងជាម្តាយធម៌ទៅជិតផ្ទាល់ សួរសុខទុក្ខពាល់មិនសល់សព្វ ។
សួរសាកម៉ែឪនៅភូមិស្រុក ថាម៉ែមើលមុខមិនហ៊ានស្អប់
ទើបនាងម្តាយធម៌ថាដូចថប់ កូនដើមមកផ្ទប់ផ្សៀននៅកាយ ។
ទុំឆ្លើយថាខ្ញុំសុំប្រណិប័តន៍ ពាន់ស្ងាត់ជម្រាបរៀបរាប់កាយ
ខ្លួនខ្ញុំសូមសុំឲ្យលោកម្តាយ ចិត្តពុំទៀយណាយពាយសម្តី ។
ភរកូតកុហកឲ្យកលាក់បាំង មកនេះខ្ញុំអាងត្បិតពារស្រី
